# អ្នកនាំសារ
The Messenger

23

ខែ ឧសភា ឆ្នាំ ២០០៥- ព័ត៌មានពីព្រះសហគមន៍កាតូលិក



# “HABEMUS PAPAM*”
# BENEDICTO XVI

*យើងមានសម្តេចប៉ាបថ្មីហើយ



តម្លៃជីវិត!
ទំនួលខុសត្រូវនៃ
អ្នករាល់គ្នា
ទំព័រ ២



ពិធីគោរព
វិញ្ញាណក្ខន្ធ
អតីតសម្តេចប៉ាប
ទំព័រ ៨

របៀបជ្រើស
តាំងសម្តេច
ប៉ាបថ្មី
ទំព័រ ១២

អំពើឃាតកម្មដែលបង្កឡើងដោយហ្វូងមហាជនបានកើនឡើងជាលំដាប់ ខណៈពេលដែលគ្មានការដាក់ទណ្ឌកម្មចំពោះជនដែលដល់។ ជាញឹកញយ ពេលជនសង្ស័យត្រូវបានចាប់ខ្លួន ឬតាមទាន់ ប្រជាជនតែងចោមរោមវាយ ពេលខ្លះរហូតដល់ថ្នាក់សម្លាប់។ ជីវិតជនសង្ស័យត្រូវបាត់រលត់ក្រោមកំហឹងរបស់មហាជនពីព្រោះគេបានឱ្យតម្លៃសំភារៈថ្លៃជាងជីវិតមនុស្សទៅវិញ។ "អ្នកនាំសារ" បានធ្វើការអង្កេតលើហេតុការណ៍នេះផ្ទាល់ ហើយក៏បានជួបបុគ្គល និងស្ថាប័នមួយចំនួនផងដែរ ដែលពន្យល់យើងឱ្យបានយល់កាន់តែច្បាស់អំពីអំពើហិង្សានៅក្នុងសង្គមកម្ពុជា។ តើតម្លៃជីវិតមនុស្សបច្ចុប្បន្នធ្លាក់ចុះដល់កំរិតត្រឹមណា?



ជនរងគ្រោះដែលត្រូវមហាជនចោមរោមវាយក្រោយពីមានការស្រែកឆោឡោឡើងថា "គេគឺជាចោរ"

Image: Yi Sok San

# តម្លៃជីវិត! ទំនួលខុសត្រូវនៃអ្នករាល់គ្នា



Photo: DR

នៅលេខក្រោយៗ នឹងមានអត្ថបទអង្កេតមួយចំនួនទៀត ដូចជា **រូបភាពនៃអំពើហិង្សាក្នុងសង្គម និងកង្វះការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ។ល។** បើប្រិយមិត្ត មានចំណាប់អារម្មណ៍នឹងពិភាក្សាលើអត្ថបទសូមផ្ញើសំបុត្រមក "អ្នកនាំសារ" តាមរយៈលោកឪពុកនៅជិតបំផុត។

សន្ទឹកជើងរបស់ហ្វូងមនុស្សបានបង្កើតជាធូលីហុយសំពោងនៅតាមបណ្ដោយផ្លូវលេខ២៧៤ ក្រោយខណ្ឌ៧មករា។ ជាមួយគ្នានេះសម្រែកព្រមៗគ្នាស្រែកឡើង «ចោរ! ចោរ!»។ ខ្លះជិះម៉ូតូ ខ្លះថ្មើរជើង មនុស្សទាំងនោះព្រួតគ្នា ចាប់វាយយុវជន ២រូប។ គេមិនយកជនសង្ស័យនោះទៅប៉ុស្តិ៍ប៉ូលីសទេ ប៉ុន្តែមហាជនប្រមាណ៣០នាក់ ដែលភាគច្រើនជាបុរសបែរជាសំរេចកាត់ក្តីដោយខ្លួនឯង។ ជនសង្ស័យទាំង២ ត្រូវទទួលរងការវាយតប់ និងទាត់ធាក់ដោយអ្នកមានកំហឹងប្រមាណ ១០នាក់។ ចំនែក អ្នកធ្វើដំណើរតាមផ្លូវ និងអ្នកនៅក្បែរខាង ឱបដៃឈរមើលប្រៀបដូចជាកំពុងគយគន់ទស្សនីយភាពអ្វីមួយ។ អ្នកទាំងនោះហាក់ដូចជាបាត់បង់នូវសីលធម៌ផ្ទាល់ខ្លួនអស់ ទុកឱ្យមនុស្សមានគ្រោះថ្នាក់ ត្រូវគេវាយសម្លាប់។ សំណាងល្អ ជនសង្ស័យនោះក៏ត្រូវបានជនបរទេសម្នាក់ជួយសង្គ្រោះ។ លោកវណ្ណាបានឃើញព្រឹត្តិការណ៍នេះដែរ ប៉ុន្តែគាត់គ្មានលទ្ធភាពអាចជួយ«ចោរ» ដែលគេកំពុងវាយយ៉ាងចាស់ដៃនោះបាន។ គាត់និយាយបែបអស់សង្ឃឹមថា: "បើខ្ញុំចូលធ្វើអន្តរាគមន៍ជួយ (ចោរនោះ) គេប្រាកដជាវាយខ្ញុំដែរដោយចោទថាចូលដៃជើងជាមួយចោរ។ ដោយខ្ញុំជាខ្មែរ វាពិបាកណាស់ក្នុងការចូលជួយ។ បើជាបរទេសមិនមាននរណាហ៊ានវាយដំលើរូបគេនោះទេ"។

ជាធម្មតាពេលប្រជាជនកំពុងតែចោមរោមវាយសម្លាប់ ជនរងគ្រោះហាក់លែងក្លាយជាមនុស្ស។ ផ្ទុយទៅវិញ មហាជនដែលដល់ និងអ្នកឈរមើលសុទ្ធតែជាខ្មែរដូចគ្នា។ តើតម្លៃនៃជីវិតមនុស្សស្ថិតនៅឯណា? គេបានបញ្ចុះជីវិតមនុស្ស មកត្រឹមកំរិតទាបសឹងតែអាចកាត់ថ្លៃបាន ដែលនេះមិនខុសគ្នាពីទំនិញដាក់លក់នៅលើទីផ្សារឡើយ។

**«ករណីមានអ្នកស្លាប់ គេសងតែពី១០០ ទៅ២០០ ដុល្លារប៉ុណ្ណោះដើម្បីធ្វើបុណ្យបូជា»**

នៅបច្ចុប្បន្ននេះ តម្លៃនៃជីវិតមនុស្សសឹងតែត្រូវបានគេដាក់ប្រកាសជាសាធារណៈទៅហើយ ពិសេសករណីគ្រោះថ្នាក់ចរាចរណ៍ ដែលតែងតែមានឃើញចុះផ្សាយតាមទំព័រសារព័ត៌មាន។ តម្លៃជីវិតអ្នករងរបួស ឬអ្នកស្លាប់បាត់បង់ជីវិតត្រូវបានបង្រួមមកស្មើត្រឹមនឹងក្រដាសប្រាក់ដុល្លារអាមេរិកប៉ុន្មានសន្លឹកប៉ុណ្ណោះ។ លោក ហែម សំបូរ ដែលធ្លាប់មានគ្រោះថ្នាក់ចរាចរណ៍ផ្ទាល់បានឱ្យដឹងថា: "កន្លងមកគេច្រើនធ្វើការសម្រុះសម្រួល ហើយទុកច្បាប់នៅមួយកន្លែងសិន។

**បទល្មើសអកម្ម**

ពាក្យនេះមានន័យសំដៅទៅលើកាតព្វកិច្ចរបស់ពលរដ្ឋទូទៅក្នុងការចូលរួមឃាត់ឃាំងនៅពេលឃើញមានឃាតកម្មដែលបង្កឡើងដោយហ្វូងមហាជន។ នៅក្នុងករណីមាននរណាម្នាក់បានឃើញហេតុការណ៍នេះ ហើយគេចវេសមិនចូលជួយជនដែលត្រូវគេវាយដំទេនោះ បុគ្គលនោះអាចទទួលទោសដាក់ពន្ធធនាគារ និងបង់ប្រាក់ពិន័យជាច្រើន។

ករណីមានអ្នកស្លាប់ គេអាចសងតែពី១០០ ទៅ២០០ដុល្លារប៉ុណ្ណោះ ដើម្បីធ្វើបុណ្យបូជា។ គេតែងនិយាយថា បុកស្លាប់អស់លុយតិចជាងរបួស ពីព្រោះត្រូវសងអស់រាប់ពាន់ដុល្លារបើអ្នករងគ្រោះពិការ"។ លោក សារិន ជាអ្នកបើកបររថយន្តដឹកភ្ញៀវយល់ស្របចំពោះសំដីបែបនេះ។ លោកបញ្ជាក់បន្ថែមថា: "គេនឹងសងប្រាក់តិចពេលជនរងគ្រោះជាគ្រួសារអ្នកក្រីក្រទន់ខ្សោយ ប៉ុន្តែគេអាចសងច្រើនប្រសិនអ្នកនោះស្ថិតនៅក្នុងគ្រួសារអ្នកមានលុយ និងអំណាច"។

**សង្គមស៊ីវិលចង្អុលដាក់ប៉ូលីស និងតុលាការ**

រយៈពេល៩ខែ ដើមឆ្នាំ២០០៥នេះ តាមស្ថិតិរបស់អង្គការសិទ្ធិមនុស្ស លីកាដូ បានឱ្យដឹងថា អំពើឃាតកម្មដោយហ្វូងមហាជនមានកើតឡើងចំនួន៧ករណី។ តួលេខនេះគឺអាចកើនឡើងថែមលើសឆ្នាំមុនៗ ប្រសិនបើគ្មានការចាត់វិធានការណ៍ផ្លូវច្បាប់ដើម្បីទប់ស្កាត់ទេនោះ។ លោក នី ចរិយា ប្រធានផ្នែកស៊ើបអង្កេត សមាគមអាដហុក បានឱ្យដឹងថា: "ការកើនឡើងបែបនេះគឺដោយសារប្រជាជនបាត់បង់ជំនឿលើសមត្ថកិច្ចប៉ូលីស និងតុលាការ។ ប្រជាជនបារម្ភថាពេលចាប់ចោរបាន ប៉ូលីស ឬតុលាការដោះលែងចោរនោះវិញ"។

ភាពមិនប្រក្រតីក្នុងប្រព័ន្ធតុលាការត្រូវបានគេដឹងឮថា ពិតជាមានការស៊ីសំណូក និងការកាត់ក្តីអយុត្តិធម៌។ មន្ត្រីឃ្លាំមើលការរំលោភសិទ្ធិមនុស្សម្នាក់របស់អង្គការលីកាដូ បានអះអាងថា: "ចៅក្រមខ្លះពុករលួយកាត់ក្តីពីខ្មៅទៅសដែលធ្វើឱ្យប្រជាពលរដ្ឋខឹងសំបារ"។ កន្លងទៅថ្មីៗនេះ មានលេចឮករណីដោះលែងជនល្មើស២៧៤នាក់ដោយ «មិនប្រក្រតី» ដែលជាប់សង្ស័យពីបទឧក្រិដ្ឋ។ ចៅក្រមព្រះរាជអាជ្ញា និងក្រឡាបញ្ជី១ចំនួន កំពុងស្ថិតក្រោមការស៊ើបអង្កេតចំពោះកំហុសពីក្រុមប្រឹក្សាវិន័យនៃឧត្តមប្រឹក្សាអង្គចៅក្រម។

សព្វថ្ងៃនេះ ប្រសិទ្ធភាពនៃការគោរពច្បាប់កំពុងតែស្ថិតក្នុងភាពស្រពិចស្រពិល។ ក្រៅពីកង្វះយុត្តិធម៌តុលាការ ចរិតលក្ខណៈរបស់សមត្ថកិច្ចប៉ូលីសមួយចំនួនបានធ្វើឱ្យប្រជាជនអស់សង្ឃឹម។ លោកមេធាវី សុក សំអឿន នាយកប្រតិបត្តិក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាបានពន្យល់ថា: "ពេលខ្លះមានប៉ូលីសបើកដៃឱ្យប្រជាជនវាយចោរដោយសារការស្អប់គុំកួនអ្វីមួយ។ ប៉ូលីសមួយចំនួនកោសរូសលុយកាក់ពីចោរហើយលែងទៅវិញ"។ ទាក់ទិនទៅនឹងការរិះគន់បែបនេះ លោក ហេង ពៅ ស្នងការនគរបាល រាជធានីភ្នំពេញ បានយល់ស្របទាំងស្រុង។ លោកឧត្តមសេនីយ៍ត្រីរូបនេះ បានលើករឿងអាស្រូវនេះជាចំហនៅក្នុងសិក្ខាសាលាស្តីពីការកែលំអប្រព័ន្ធយុត្តិធម៌ថា: "ជាក់ស្តែង ករណីឆក់ក្រវិលពេជ្រថៅកែហាង «ទន្លេសាប» ដែលក្រវិលម្ខាងៗ មានតម្លៃដល់ទៅ ២៥០០ដុល្លារ។ ប៉ូលីសចាប់ចោរបានហើយ ឱ្យចោរនោះប្រមូលលុយមកសង។ ប៉ូលីសបានព្រលែងចោរក្រោយពីបានទទួលលុយ ១០០០ ដុល្លារពីចោរ ហើយជនរងគ្រោះបានលុយតែ ១៥០០ដុល្លារមកវិញប៉ុណ្ណោះ។ បច្ចុប្បន្ន យើងកំពុងធ្វើកំណែទម្រង់ផ្ទៃក្នុងដើម្បីបោសសំអាតមន្ត្រីខូច"។

**«យើងគ្រាន់តែចាត់ចូលទៅក្នុងកង្វះខាតផ្នែកសីលធម៌ប៉ុណ្ណោះ»**

ផ្អែកលើមាត្រាទី២៥ នៃច្បាប់ព្រហ្មទណ្ឌ សម័យអន្តរកាល (ឆ្នាំ១៩៩២) ស្តីពីការសន្មតជាមុនថាគ្មានទោសបានចែងថា «គ្រប់ជនដែលគេសង្ស័យ គ្រប់ជនជាប់ពិរុទ្ធ គ្រប់ជនជាប់ចោទត្រូវទទួលការសន្មតមុនថា គ្មានកំហុសជាដាច់ខាត»។ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាក៏បានធានាអះអាងបន្ថែមទៀតថា: «ទោសប្រហារជីវិតត្រូវបានលុបចោល នៅក្នុងប្រទេសកម្ពុជា»។ ដូចនេះ គ្មានហេតុផលអ្វីត្រូវសម្លាប់ជនសង្ស័យឡើយ។ «បទល្មើសអកម្ម» ជាផ្នែកមួយសំខាន់ដើម្បីពញ្ញាក់ស្មារតីមហាជន។ លោក សេង ស៊ីរ៉ុថា ដែលជា...

ប្រធាននាយកដ្ឋានព្រហ្មទណ្ឌក្រសួងយុត្តិធម៌បានឱ្យដឹងថា: "អកម្មបទល្មើសពុំមានចែងក្នុងពង្រាង នៃក្រមរដ្ឋប្បវេណីទេ។ ដូច្នេះ ចំពោះបុគ្គលណាដែលខកខានពុំបានឃាត់ឃាំងការវាយប្រហារលើជនសង្ស័យ យើងគ្រាន់តែចាត់ចូលទៅក្នុងការកង្វះខាតខាងផ្នែកសីលធម៌ប៉ុណ្ណោះ"។

**តើនរណាអប់រំតម្លៃជីវិតមនុស្សដល់យុវជន?**

លោកបណ្ឌិត ឡៅ ម៉ុងហៃ ទីប្រឹក្សាច្បាប់នៃមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមបានចាត់ទុកបុព្វហេតុ នៃការកើនឡើង នៃអំពើហិង្សានេះថាដោយសារតែសង្គ្រាមដែលធ្វើឱ្យសីលធម៌រស់នៅរបស់ប្រជាជនខ្មែរយើងធ្លាក់ចុះ។

លោកបានអះអាងថា: "យើងមិនឱ្យតម្លៃមនុស្សដោយសារយើងមិនធ្វើសមាមាត្ររវាងទោស និងកំហុស។ គេមិនអាចសម្លាប់មនុស្សដោយសារតែទូរស័ព្ទដៃ១បានទេ"។ ជាមួយគ្នានេះ ភាពជ្រុលនិយមរបស់ប្រជាជនខ្មែរ ក៏ជាមូលហេតុ១នៃអំពើហិង្សាផងដែរ។ លោកបណ្ឌិតបានបន្ថែមថា: "ការប្រដៅក្នុងគ្រួសារ យើងតែងស្តីកូនចៅដោយប្រើពាក្យ ដូចជា "ដាក់ឱ្យងាប់"។ ទាំងនេះវាជ្រុលហួសហេតុពេក"។

ពេលនេះ សីលធម៌បង្រៀនក្នុងកម្មវិធីថ្នាក់ទី១១ និងទី១២ ក៏មាននិយាយពីតម្លៃមនុស្សផងដែរ។ ប៉ុន្តែ នៅខ្វះភាពទូលំទូលាយ និងឧទាហរណ៍។ លោក ម៉ាន់ និរ៉ុឌ្ឍន៍ គ្រូបង្រៀនពលរដ្ឋវិជ្ជានៅវិទ្យាល័យ វាលវេញ គូសបញ្ជាក់ថា: "យើងពុំបានបង្រៀនឱ្យស៊ីជំរៅណាស់ណាទេ។ សិស្សគ្រាន់តែដឹងពីការស្រលាញ់ជីវិត និងការសាបព្រោះព្រហ្មវិហារធម៌។ យើងពុំបានលើកឧទាហរណ៍ជាក់ស្តែងក្នុងសង្គមមកពន្យល់សិស្សទេ"។

សំរាប់សង្គមនីមួយៗ មនុស្សចាំបាច់រស់នៅក្នុងកិត្តិយស។ ការកំនត់តម្លៃជីវិតមនុស្សប្រៀបធៀបទៅនឹងតម្លៃសំភារៈ មិនអាចកែលំអន្នូវច្បាប់សង្គមនោះបានទេ។ ព្រះតេជគុណ ហឿន សំណៀង តំណាងអង្គការ SCC នៅវត្តថ្មី ខេត្តសៀមរាប ដែលតែងជួយថែទាំអ្នកផ្ទុក និងអ្នកជំងឺអេដស៍ បានពន្យល់ថា: "ជីវិតគឺជាការរស់នៅរបស់មនុស្ស និងសព្វសត្វទាំងឡាយទាំងពួង។ គោលបំណងនៃការស្វែងរកសេចក្តីសុខរបស់មនុស្សម្នាក់ៗ មិនដូចគ្នាទេ។ អ្នកដើរលួចប្លន់គេមានសេចក្តីល្ងង់ខ្លៅដោយគេចង់បានសេចក្តីសុខខុសន្នូវបែបបទ។ ដូច្នេះបើប្រជាជនវាយសម្លាប់គេនោះ គឺពួកគាត់កាន់តែល្ងង់ជាងជនទាំងនោះទៅទៀត»។ តាមពិត ការស្វែងរកយុត្តិធម៌ដោយសម្លាប់មនុស្ស មិនអាចកាត់បន្ថយអំពើចោរកម្មបានទេ។ រឿងរ៉ាវដែលប្រជាជនព្រួតគ្នាវាយជនសង្ស័យឆ្លុះបញ្ចាំងឱ្យឃើញច្បាស់នូវអំពើហិង្សានៅក្នុងប្រទេស។

បូលីន ដារិដ

## ឃាតកម្មដោយមហាជនកាន់តែគួរឱ្យបារម្ភ

ក្នុងឆ្នាំ២០០៤ មានករណីឃាតកម្មដោយហ្វូងមហាជនចំនួន២២ករណី។ ចំនួននេះកើនឡើងប្រមាណជា៣ដង បើប្រៀបធៀបទៅនឹងឆ្នាំ២០០៣កន្លងមក មាន៧ករណី។ សំរាប់ឆ្នាំ២០០៤ អំពើឃាតកម្ម២២ករណី បង្កឱ្យមានជនរងគ្រោះ ២១នាក់ស្លាប់ និង១៩នាក់ រងរបួសធ្ងន់ធ្ងរ។ ករណីឃាតកម្មដោយហ្វូងមហាជនកើតឡើងភាគច្រើននៅក្នុងរាជធានីភ្នំពេញ។

## ជីវិតមនុស្សជាជីវិតមួយដ៏វិសុទ្ធ

ទស្សនវិជ្ជាគ្រិស្តសាសនាបានអះអាងថា ជីវិតមនុស្សជាតិម្នាក់ៗ មានតម្លៃពិសិដ្ឋតាំងពីពេលចាប់កំណើតរហូតដល់ទទួលមរណភាព។ នៅក្នុងរយៈពេល ២០០០ឆ្នាំមកនេះ គ្រិស្តបរិស័ទបានតស៊ូស្វែងរកតម្លៃជីវិតដ៏ឧត្តុង្គឧត្តមបំផុតរបស់មនុស្ស ដែលមានឫសគល់ចេញពីព្រះជាម្ចាស់។ គ្រប់សាសនាដ៏ចម្បងៗទាំងអស់បានទទួលស្គាល់សេចក្តីថ្លៃថ្នូរ និងតម្លៃបុគ្គលម្នាក់ៗ ដោយមិនអាចគណនា និងកាត់ថ្លៃបាន ទោះបីអ្នកនោះជាអ្នកមានឋានៈ ភេទ កំរិតវប្បធម៌អប់រំត្រឹមណាក៏ដោយ។ យើងនៅតែចងចាំជានិច្ចក្នុងដួងចិត្ត និងក្រអៅបេះដូងពីប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតរបស់កម្ពុជាយើងថ្មីៗនេះ ជាពិសេសក្នុងរបបប៉ុលពត ដែលជំរុញឱ្យយើងខិតខំបង្កើននូវការប្តេជ្ញាចិត្តក្នុងការការពារ និងគោរពជីវិតមនុស្សគ្រប់ទម្រង់ទាំងអស់។ វាជារឿងដ៏គួរឱ្យរន្ធត់បំផុត ដែលធ្វើឱ្យមនុស្សហ៊ានសម្លាប់គ្នាប្រៀបដូចសត្វធាតុ។

ជារឿយៗ ខ្ញុំមានការឈឺចាប់ ពេលដែលខ្ញុំបានអាន និងបានស្តាប់រឿងរ៉ាវដ៏ព្រៃផ្សៃរបស់មនុស្សក្នុងសង្គមរបស់យើងក្នុងការប្រព្រឹត្តសកម្មភាពប្រឆាំងនឹងអ្នកដទៃ ពិសេសចំពោះអ្នកក្រីក្រទន់ខ្សោយ និងគ្មានទីរំពឹង។ យើងអាចសួរខ្លួនឯងថា: តើយើងអាចធ្វើអ្វីបានដើម្បីបញ្ឈប់បញ្ហានេះ? មិនថាជាបងប្អូនមានជំនឿលើសាសនា ឬមិនមាន បងប្អូនប្រណិប័តន៍តាមព្រះពុទ្ធសាសនា ឥស្លាមសាសនា គ្រិស្តសាសនា ឬសាសនាដទៃទៀតក៏ដោយ តើបងប្អូនគួរតែប្តេជ្ញាចិត្តយ៉ាងណាដើម្បីការពារតម្លៃជីវិតរបស់មនុស្ស?

អតីតសម្តេចប៉ាប យ៉ូហាន ប៉ូលទី២ ព្រះអង្គបានព្រះលិខិតនូវព្រះរាជសារដ៏មានខ្លឹមសារមួយ គឺ «The Gospel of Life» ដែលមានន័យថា: "ដំណឹងល្អនៃជីវិត" ដែលយើងទាំងអស់គ្នាគួរតែជ្រាប និងអនុវត្តតាម។ នៅក្នុងព្រះរាជសារលិខិតនេះ សម្តេចទ្រង់ព្រះលិខិតអំពីតម្រូវការជាបន្ទាន់ទៅក្នុងសង្គមទំនើបដើម្បីគោរពជីវិតរបស់មនុស្ស និងជំរុញឱ្យរដ្ឋាភិបាលគ្រប់ជាតិសាសន៍ទាំងអស់បង្កើតច្បាប់ និងប្រព័ន្ធតុលាការប្រកបទៅដោយភាពយុត្តិធម៌ក្នុងការការពារជីវិតមនុស្ស ជាពិសេសអស់អ្នក ដែលទន់ខ្សោយដូចជាប្រជាជនដែលក្រីក្របំផុតនៅក្នុងប្រជាជាតិនីមួយៗ។

ទីបញ្ចប់ ខ្ញុំសូមអញ្ជើញ បងប្អូនរិះគិតអំពីប្រធានបទដ៏មានសារៈសំខាន់នេះ ដោយចែកជាក្រុមតូចៗ ហើយធ្វើការសន្និដ្ឋាន និងធ្វើការប្តេជ្ញាចិត្តចំពោះការការពារតម្លៃជីវិតរបស់មនុស្ស។

លោកឪពុក អ្នូ មែរ





# ចំន្ទ វិត្ថារិទ្ធ ដក់ចិត្តនឹងក្បាច់ខ្មែរ

**លោកបានចំណាយអស់រយៈពេល៤ឆ្នាំ ដើម្បីធ្វើការចងក្រងសៀវភៅមួយក្បាល កំរាស់រហូតដល់៤៣០ទំព័រ ស្តីអំពីក្បាច់ខ្មែរ ដែលនៅក្នុងនោះមានរូបភាពជារូបថតផង និងគូរដោយដៃផង។**



Photo: M. Kunthear

លោក ចំន្ទ វិត្ថារិទ្ធ ចង្អុលបង្ហាញអំពីទម្រង់ក្បាច់សិល្បៈខ្មែរ ដែលតាំងនៅអង្គការរ៉ែយំ

នៅលើជញ្ជាំងក្នុងអគាររបស់អង្គការរ៉ែយំ គេឃើញមានរូបភាព ទាំងរូបថត និង រូបគូរដោយដៃកំពុងបង្ហាញខ្លួនយ៉ាងសង្ហាជូនអ្នកទស្សនា ព្រមទាំងសៀវភៅនិយាយអំពីក្បាច់ខ្មែរដែលគួរជាទីចាប់ចិត្តដែលកំពុងតែផ្តេកខ្លួន នៅលើតុចំកណ្តាលបន្ទប់អគារ។

ក្រោមសម្លៀកបំពាក់អាវឆ្នូតពណ៌ក្រហមដៃខ្លី ជាមួយនឹងទឹកមុខញញឹមពីចម្ងាយ ដែលកំពុងធ្វើដំណើរយ៉ាងស្វាហាប់ភ្ជាប់ដោយកាតាបស្ពាយពណ៌ខ្មៅមួយនៅជាប់នឹងស្មាមកជាមួយផងនោះ គឺលោក ចំន្ទ វិត្ថារិទ្ធ ។ លោកគឺជាបុគ្គលិកនៃអង្គការរ៉ែយំ (អ្នកស្រាវជ្រាវ) និងជាសាស្ត្រាចារ្យផ្នែកថតរូប និងផ្នែកវិចិត្រកម្ម នៅមហាវិទ្យាល័យវិចិត្រសិល្បៈសូនរូប។ លោកបានធ្វើការសិក្សាពីក្បាច់ខ្មែរនេះ អស់រយៈពេល៤ឆ្នាំមកហើយ។ លោកបានចូលរៀននៅសាលារចនាតាំងពីឆ្នាំ១៩៨៦មកម្ល៉េះ។ លោកចំន្ទ វិត្ថារិទ្ធ បានមានប្រសាសន៍ឱ្យដឹងថា ការដែលលោកចេះគូរនេះក៏ដោយសារតែ នៅក្នុងវិជ្ជាជីវៈមូលដ្ឋាននៅក្នុងសាលា គេបានបង្រៀន និងលោកបានធ្វើការស្រាវជ្រាវដោយខ្លួនឯងបន្ថែម នូវក្បាច់ខ្មែរទាំងនោះតាមរយៈឯកសារ ការសាកសួរលោកគ្រូចាស់ៗ និងរុករកនៅតាមប្រាសាទនានាក្នុងប្រទេសកម្ពុជាយើង ដែលក្នុងនោះលោកបានលើកយកក្បាច់ខ្មែរសំខាន់ៗ ចំនួន៤ ធំៗ គឺក្បាច់អង្គរ ក្បាច់ភ្ញីទេស ក្បាច់ភ្ញីវល្លិ៍ និងក្បាច់ភ្ញីភ្លើង ព្រមទាំងក្បាច់ជាមូលដ្ឋានជាច្រើនទៀតដាក់ក្នុងសៀវភៅដើម្បីទុកជាឯកសារផងដែរ។ លោកបានបន្តទៀតថា វាគឺជាការពិបាកមែនទែនដោយសារតែមិនសូវមាន ឯកសារដែលជាសន្លឹកសំរាប់បង្ហាញ គឺមានតែនៅក្នុងចម្លាក់។

បុរសពាក់កណ្តាលមជ្ឈិមវ័យរូបនេះបានបន្តសំដីរបស់គាត់ទៀតថា: "កាលនៅពីតូចខ្ញុំពុំដែលមានគោលបំណងអ្វីទេ គឺខ្ញុំទើបតែចាប់ផ្តើមនៅឆ្នាំ១៩៩៨ នៅពេល ដែលខ្ញុំប្រឡងចប់បរិញ្ញាប័ត្រ"។ លោកបន្តសំដីដោយសម្លេងមួយៗថា: "ការងារនេះមានការពិបាកដោយសារតែពេលចាប់ផ្តើមដំបូងឃើញថា វាហាក់ដូចជាមានភាពតិចតួច តែដល់ពេលធ្វើទៅកាន់តែច្រើនឡើងៗ ដូចជាក្នុងការប្រៀបធៀបគ្នាបែងចែករវាងក្បាច់ភ្ញីទេស និងភ្ញីវល្លិ៍ ព្រោះក្បាច់ពីរនេះ វាស្ទើរតែស្រដៀងគ្នា ដែលមានលក្ខណៈពិសេសតិចតួចដែលអាចឱ្យយើងសម្គាល់បាន"។

លោក ចំន្ទ វិត្ថារិទ្ធ បញ្ចេញសម្លេងបណ្តើរបើកសៀវភៅដែលមានក្របពណ៌ក្រហមឆ្អិនឆ្អៅរបស់លោកមើលបណ្តើរថា: "អ្វីដែលធ្វើឱ្យអ្នកទស្សនាចាប់អារម្មណ៍លើរូបទាំងនេះដោយសារតែស្ទើរទាំងអស់នៃរូប ខ្ញុំបង្ហាញពីការគូរតាមវិធីសាស្ត្រមួយដែលមិនធ្លាប់មានពីមុនមក"។ តាមពិត គោលបំណងលោក ចំន្ទ វិត្ថារិទ្ធ ដែលធ្វើជាសៀវភៅ និយាយអំពីក្បាច់ខ្មែរនេះឡើងគឺដើម្បីបន្សល់ទុកជាឯកសារដ៏មានតម្លៃ ឬក៏ជាផ្លូវតូចមួយសំរាប់ឱ្យអ្នកជំនាន់ក្រោយ ដែលចង់ស្រាវជ្រាវ ឬចង់សិក្សាបន្ថែមពីលើនេះ។ ចំពោះការបង្កើតក្បាច់ថ្មីសុទ្ធសាធតែម្តងនោះ លោកមិនទាន់ហ៊ានអះអាងឡើងថាលោកអាចធ្វើបាននោះទេ។ លោកបានបញ្ជាក់ថា យើងមិនទាន់បានជ្រមុជជ្រៅទៅលើកាលបរិច្ឆេទ ឬសម័យកាលទេ ព្រោះគ្មានឯកសារណាមួយដែលបង្ហាញច្បាស់។ កាលដែលយើងធ្វើគឺយើងគ្រាន់តែគិតអំពីទម្រង់ពីធម្មជាតិជាមួយនឹងទម្រង់ក្បាច់ដែលយើងឃើញសព្វថ្ងៃនេះ។

មុំ គន្ធា

## ទម្រង់ក្បាច់មូលដ្ឋានមានច្រើន

ក្រៅពីក្បាច់មូលដ្ឋានធំទាំងបួន ក្បាច់ខ្មែរមានច្រើនទម្រង់ទៀតដូចជា ទម្រង់ត្របកឈូកចំពីមុខ និងស្លឹកពោធិ៍ ទម្រង់ត្របកឈូកចំហៀង ឬកន្ទុយហង្ស ទម្រង់ទ្រនុងនាគ ទម្រង់សំបកទំពាំង ទម្រង់ពងត្រី ទម្រង់ហៀន ទម្រង់វង់ហៀន ឬគូថខ្យង ទម្រង់ក្បាច់ធ្មេញត្រី ទម្រង់ក្បាច់ធ្មេញក្របី ទម្រង់ក្បាច់កេសរ និងទម្រង់ក្បាច់កញ្ចាំង។ល។



Photo: DR

**យើងសូមធ្វើការរំឭកដល់វិញ្ញាណក្ខន្ធប្រជាជនដែលបានទទួលមរណភាពក្នុងព្រឹត្តិការណ៍វិវាទដីធ្លី នៅទីប្រជុំជនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ!**

# CSC ផ្តល់រង្វាន់ដល់អ្នកមានស្នាដៃ




Photo: P. Samphy

លោកឪពុកអូមែរប្រគល់រង្វាន់ដល់ជ័យលាភីកំណាព្យលេខ១

កាដូលើកទឹកចិត្ត និងបាច់ផ្កាត្រូវ បានផ្តល់ដល់អ្នក ដែលមានស្នាដៃនិពន្ធកំណាព្យនាព្រឹកថ្ងៃសៅរ៍ ទី៣០ មេសា នៅការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក។ ក្នុងនោះ មានអ្នកស្រី ខុង ណារី និង លោក ឡុង សម្ផស្ស ដែលចូលរួមប្រឡងស្នាដៃខាងការនិពន្ធកំណាព្យដែលរៀបចំឡើង កាលពីខែកញ្ញា ២០០៤កន្លងទៅនេះ។ អ្នកស្រី ខុង ណារី ជ័យលាភីលេខ១ មានប្រសាសន៍ ក្នុងឱកាសនោះថា: "ខ្ញុំមិនដែលបានរៀនតែងកំណាព្យ ពីគ្រូណាទេពីមុនមក វាជាដុងពីធម្មជាតិរបស់ខ្ញុំ។ ខ្ញុំមានគំនិត និងចំនង់ចំនូលចិត្តតែងកំណាព្យដើម្បីចូលរួមផ្សព្វផ្សាយវប្បធម៌ខ្មែរ"។ អត្ថបទកំណាព្យរបស់អ្នកស្រី មានចំនងជើងថា "ដើមត្នោតមាស" បង្ហាញអំពីអត្ថប្រយោជន៍ដ៏មហិមារបស់ដើមត្នោត។ រង្វាន់ទី២ គឺបានទៅលោក ឡុង សម្ផស្ស ដែលជាម្ចាស់កំណាព្យ "ខ្ញុំអ្នកនាំសារ" ដោយអត្ថន័យផ្តោតទៅលើផលវិបាក និងការខិតខំធ្វើការរបស់ "អ្នកនាំសារ"។ លោកបាននិយាយនៅខណៈនោះថា កំណាព្យ ដែលមានភាពទាក់ទាញ គឺត្រូវមានអត្ថន័យអប់រំល្អ និងមានចំណាប់ចុងជួនត្រឹមត្រូវ។

លោកឪពុកអូម៉ែរ បាននិយាយថា: "វាគឺជាសេចក្តីរីករាយណាស់សំរាប់ពួកយើង ដោយដឹងថា មានមនុស្សជាច្រើនកំពុងតែសរសេររឿងនិងកំណាព្យ។ នេះជាមធ្យោបាយមួយដ៏ល្អបំផុត ដើម្បីជួយលើកតម្កើងនូវវប្បធម៌ខ្មែរឱ្យកាន់តែរីកចំរើនឡើងថែមទៀត"។

មុំ គន្ធា

## សុខភាព



Photo: Fr. Omer

លោកស្រី Marissa Regeno-Manampan វេជ្ជបណ្ឌិត ជំងឺកុមារ នៃគ្លីនិកសហគមន៍ និង គ្រួសារពេទ្យ

### តើជម្ងឺរាគរូសជាអ្វី?

រាគគឺជាជម្ងឺមួយដែលកើតឡើង ដោយសារកង្វះអនាម័យនៅក្នុងជីវភាពរស់នៅ ដូចជា ការហូបទឹកមិនស្អាត ទឹកឆៅ ការមិនមានអនាម័យខ្លួនប្រាណ និង កង្វះអនាម័យក្នុងការលាងសំអាតបន្លែផ្លែឈើជាដើម។

ជម្ងឺនេះតែងបណ្តាលមក ពីមូលហេតុសំខាន់ៗចំនួន ៤យ៉ាង គឺ ទី១ បង្កឡើងដោយបាក់តេរី ទី២ វីរុស ទី៣ ប៉ារ៉ាស៊ីត និងចុងក្រោយគឺចំណីអាហារដែលមានសារជាតិពុល។ ជាទូទៅអ្នកជម្ងឺរាគមានអាការៈចុកពោះ និងរាគរូសជាបន្តបន្ទាប់គ្នាលើសពីចំនួន៣ថ្ងៃ។ ដើម្បីព្យាបាលជម្ងឺរាគឱ្យមានប្រសិទ្ធភាព អ្នកជម្ងឺត្រូវតែទៅពិគ្រោះយោបល់ ជាមួយវេជ្ជបណ្ឌិតជាបន្ទាន់។ នៅពេលមានជម្ងឺរាគរូសសូមពិសារទឹក ឱ្យបានច្រើន ដូចជា ទឹកដែលមានលាយថ្នាំអូរ៉ាលីត ទឹកដូងខ្ចី ឬទឹកបបរជាដើមដើម្បីបង្គ្រប់ជាតិទឹកដែលបាត់បង់ដោយសារតែការរាគនេះ។ ចំពោះកុមារឬទារកគឺយើងត្រូវបន្តឱ្យបៅទឹកដោះម្តាយ កុំឱ្យអាក់ខានឱ្យសោះ ពីព្រោះទឹកដោះម្តាយក៏មានជាតិទឹក និងជីវជាតិគ្រប់គ្រាន់ដែលជាតម្រូវការរបស់កុមារ។ យើងអាចបន្ថែមទឹកអូរ៉ាលីតរឹតតែប្រសើរ។ ជម្ងឺរាគរូសជាទូទៅជាជម្ងឺឆ្លង ប៉ុន្តែ មិនមែនគ្រប់ប្រភេទនៃជម្ងឺរាគឆ្លងរាលដាលឡើយ។

សំ វ៉ានី





# ព្រះវិញ្ញាណគង់នៅជាមួយយើងជានិច្ច

**នៅថ្ងៃទី៥០ ក្រោយពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញរំឭកយើងទាំងអស់គ្នាដល់ថ្ងៃដែលព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណដល់ក្រុមគ្រិស្តទូត និងរំឭកថ្ងៃដែលយើងបានទទួលអគ្គសញ្ញាលាបថ្ងាស។**



Photo: DR

ក្បួនដង្ហែថ្ងៃបុណ្យព្រះវិញ្ញាណយាងមករបស់ព្រះសហគមន៍បាត់ដំបង (ឆ្នាំមុន)

ក្រុមគ្រិស្តទូតបានទទួលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ តាមព្រះបន្ទូលសន្យារបស់ព្រះយេស៊ូ ថានឹងផ្តល់ជាកម្លាំងចិត្តដល់ពួកគេដើម្បី ឱ្យពួកគេអាចទៅប្រកាសដំណឹងល្អដល់មនុស្សគ្រប់ជាតិសាសន៍។ ដោយសារពេលព្រះយេស៊ូសុគត ពួកគេភ័យខ្លាចចំពោះជនជាតិយូដាមកធ្វើបាប ពួកគេក៏នៅតែក្នុងផ្ទះ និងខ្ទាស់ទ្វារយ៉ាងជិត។ ប៉ុន្តែព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងបន្តរស់នៅជាមួយក្រុមគ្រិស្តទូតដោយបង្ហាញខ្លួនឱ្យគេឃើញអស់រយៈពេល ៤០ថ្ងៃ ទើបព្រះអង្គយាងទៅស្ថានបរមសុខ។ ព្រះអង្គក៏បានផ្តាំពួកគេមិនឱ្យចេញពីទីក្រុងយេរូសាឡឹមឡើយរហូតដល់ថ្ងៃទី៥០ ព្រះអង្គនឹងប្រទានព្រះវិញ្ញាណ ដែលជាកម្លាំងណែនាំគេចេញទៅខាងក្រៅទីក្រុង ប្រកាសដំណឹងល្អនៅគ្រប់ទីកន្លែងក្នុងពិភពលោក។ អត្ថន័យនេះមានទាក់ទងទៅនឹងព្រះគម្ពីរ សម្ព័ន្ធមេត្រីចាស់ "ដំណើរឆ្ពោះទៅកាន់សេរីភាព"។

លោកឪពុក សួន ហង្សលី បានបកស្រាយថា តាមគម្ពីរ ព្រះជាម្ចាស់បានចាត់លោកម៉ូ សេ ជាអ្នកនាំជនជាតិអ៊ីស្រាអែលចេញពីស្រុកអេហ្ស៊ីបឆ្លងដើម្បីគេចចេញពីការជិះជាន់ របស់ពួកអេហ្ស៊ីប។ ព្រះជាម្ចាស់ផ្តល់ឱ្យគេនូវសេរីភាព (នេះជាប់នឹងអត្ថន័យនៃបុណ្យចម្លង ដូចព្រះយេស៊ូមានព្រះជន្មឡើងវិញ ឆ្លងពីស្លាប់ទៅមានជីវិតរស់) បន្តរស់នៅក្នុងវាលរហោស្ថានអស់រយៈពេល៤០ឆ្នាំ ព្រះអង្គគង់នៅជាមួយពួកគេ ថែរក្សាការពារពួកគេរហូត ហើយព្រះអង្គបានប្រទាន នូវធម៌វិន័យនៃសម្ព័ន្ធមេត្រីដល់លោក ម៉ូ សេ នៅលើភ្នំដើម្បីណែនាំឱ្យពួកគេគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងរស់នៅធ្វើជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ។

ពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះអង្គគង់នៅជាមួយក្រុមគ្រិស្តទូតរយៈពេល៤០ថ្ងៃ។ នៅថ្ងៃទី៥០នេះ ព្រះជាម្ចាស់បានប្រទាននូវធម៌វិន័យថ្មីដល់យើងទាំងអស់គ្នា ដូចជាជនជាតិអ៊ីស្រាអែលនាសម័យលោក ម៉ូ សេ ដែរ។

### ផលបានមកពីព្រះវិញ្ញាណ

ផលដែលកើតចេញពីព្រះវិញ្ញាណមានសេចក្តីស្រលាញ់ អំណរ សេចក្តីសុខ ចិត្តអត់ធ្មត់ សប្បុរស ចិត្តសន្តោស ជំនឿ ចិត្តស្លូតបូត និងចេះទប់ចិត្តខ្លួនឯង។ អស់អ្នកដែលរួមជាមួយព្រះគ្រិស្តយេស៊ូ សុទ្ធតែបានឆ្កាងតណ្ហា និងការលោភលន់ផ្សេងៗចោល។ ប្រសិនបើយើងមានជីវិតដោយព្រះវិញ្ញាណមែន យើងក៏ត្រូវប្រតិបត្តិតាមព្រះវិញ្ញាណដែរ។ ត្បិតបំណងខាងលោកីយ៍តែងតែខុសទាស់ទៅនឹងបំណងខាងព្រះវិញ្ញាណ។

លោកឪពុកសួន ហង្សលី បញ្ជាក់ថា: "នេះគឺជាព្រះវិញ្ញាណដ៏វិសុទ្ធ ជាធម៌វិន័យថ្មី" ដែលគង់នៅជាមួយយើងគ្រប់វេលា និងណែនាំឱ្យ យើងរស់ក្នុងព្រះសហគមន៍ ធ្វើជាបន្ទាល់នៃសេចក្តីស្រលាញ់របស់ព្រះយេស៊ូដល់មនុស្សគ្រប់សាសន៍។

លោកឪពុកបន្តថា: "តាមប្រពៃណីព្រះសហគមន៍ គេតែងធ្វើអគ្គសញ្ញាលាបថ្ងាសនៅថ្ងៃនេះ ក្រោយពីបានទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឱកាសបុណ្យចម្លង" ដែលនេះជាសញ្ញាបញ្ជាក់ថា គេជាមនុស្សពេញវ័យក្នុងជំនឿ ហើយគេទទួលកម្លាំងពីព្រះវិញ្ញាណដើម្បីបំពេញបេសកកម្ម ក្នុងព្រះសហគមន៍។ ហើយព្រះវិញ្ញាណដ៏វិសុទ្ធ ជួយឱ្យយើងទាំងអស់គ្នាដឹងថា "យើងជាបុត្រធីតារបស់ព្រះជាម្ចាស់"។ ព្រះវិញ្ញាណនៃព្រះជាម្ចាស់ធ្វើការក្នុងយើងជានិច្ច។ ដោយធ្លាប់មានបទពិសោធន៍ លោក គង់ សាវ៉ណ្ណ គ្រិស្តបរិស័ទ ព្រះសហគមន៍កំពង់ធំបានបញ្ជាក់ថា: "ព្រះវិញ្ញាណជួយខ្ញុំឱ្យចេះនិយាយចំគោលដៅ"។ លោកលើកឧទាហរណ៍ នៅពេលលោកធ្វើធម៌អង្វរសកល ដំបូងលោកពុំដឹងនិយាយអ្វីទេ។ ប៉ុន្តែ ភ្លាមៗលោកនឹកឃើញទូលអង្វរសុំទឹកភ្លៀងពីព្រះជាម្ចាស់ ហើយថ្ងៃនោះនៅពេលរសៀល មានភ្លៀងធ្លាក់មកមែន។ ចំពោះឧបសគ្គក្នុងជីវិត លោកបញ្ជាក់ថា "ព្រះវិញ្ញាណបំភ្លឺខ្ញុំឱ្យចេះរកវិធីដោះស្រាយ និងមិនឱ្យខ្ញុំធ្លាក់ទឹកចិត្តឡើយ "។

លី សុវណ្ណា







# គោរពវិញ្ញាណក្ខន្ធអតីតសម្តេចប៉ាប









Photos: Fr. Omer, Davith, L. Sovanna



J'éprouve une profonde tristesse à la nouvelle du décès de Sa Sainteté le Pape Jean-Paul II.

Permettez-moi d'exprimer mes condoléances les plus attristées,

Norodom Sihamoni
Roi du Cambodge




**បកប្រែ:** ខ្ញុំព្រះករុណាសូមសម្តែងសេចក្តីទុក្ខព្រួយយ៉ាងជ្រាលជ្រៅចំពោះដំណឹងនៃការសោយទិវង្គតរបស់សម្តេចប៉ាប យ៉ូហាន ប៉ូលទី២។ ខ្ញុំសូមអនុញ្ញាតសម្តែងនូវមរណទុក្ខយ៉ាងក្រៀមក្រំជាទីបំផុត។ **ព្រះមហាក្សត្រកម្ពុជា!**

## គោរពវិញ្ញាណក្ខន្ធសម្តេចប៉ាប យ៉ូហាន ប៉ូលទី២

សម្តេចប៉ាបយ៉ូហាន ប៉ូលទី២ ទទួលមរណភាពនៅថ្ងៃទី២ ខែមេសា ២០០៥។ រួមជាមួយគ្រិស្តបរិស័ទទូទាំងពិភពលោក ព្រះសហគមន៍នៅប្រទេសកម្ពុជាបានរៀបចំពិធីគោរពវិញ្ញាណក្ខន្ធសម្តេចប៉ាប កាលពីថ្ងៃទី ៧ ខែមេសា ២០០៥ នៅព្រះវិហារសន្តយ៉ូសែបក្រោមអធិបតីភាពរបស់ព្រះករុណា សម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងលោកអភិបាលទាំង៣ភូមិភាគ សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិ ប៊ូគ្រី និងសម្តេចឧត្តមបញ្ញាគណៈមហានិកាយ។ ព្រះករុណាសម្តេចព្រះបរមនាថបានយាងដាក់កម្រងផ្កា២ ដើម្បីគោរពព្រះវិញ្ញាណក្ខន្ធ សម្តេចប៉ាប។ ដោយមានសរសេរអក្សរថា “ជូនចំពោះសម្តេចប៉ាបយ៉ូហាន ប៉ូលទី២ ជាមួយនឹងការគោរពដ៏ជ្រាលជ្រៅ ការដឹងគុណ និងការកោតសរសើរ”។ កម្រងផ្កានោះមួយជារបស់ព្រះវរក្សត្រនរោត្តមសីហនុជាបិតា និងមួយទៀតជារបស់ព្រះអង្គផ្ទាល់។ នៅលើជញ្ជាំងខាងក្រោយអសនៈ មានសរសេរពាក្យធំៗថា “កុំខ្លាចអី” ដែលជាព្រះបន្ទូលរបស់សម្តេចប៉ាបដើម្បីរំឭកដល់គ្រិស្តបរិស័ទទាំងអស់ឱ្យចេះផ្ញើជីវិតនៅលើព្រះជាម្ចាស់ដោយមានចិត្តក្លាហានក្នុងការប្រកាសព្រះបន្ទូល និងកសាងសន្តិភាពនៅក្នុងពិភពលោកនេះ។

លី សុវណ្ណា

## ព្រះមហាវរក្សត្រ រំឭកទៅដល់អតីតសម្តេចប៉ាប

នៅក្នុងអត្ថបទមួយនៅលើទំព័រវិបសាយ របស់អតីតព្រះមហាក្សត្រនរោត្តមសីហនុបានបង្ហាញថា ព្រះអង្គតែងតែមានការគោរពដ៏ខ្ពង់ខ្ពស់ និងការកោតសរសើរយ៉ាងជ្រាលជ្រៅគ្មានព្រំដែន ចំពោះសម្តេចប៉ាបយ៉ូហាន ប៉ូលទី២។ ព្រះអង្គសរសេរថា: “តាមទស្សនៈខ្ញុំ ពីមុនមកមិនមានសម្តេចប៉ាបណាដែលមានសកម្មភាពយ៉ាងរស់រវើកផ្តល់គុណប្រយោជន៍ដល់ប្រជាជន និងយុវជនទូទាំងពិភពលោក ដូចជាសម្តេចប៉ាបសញ្ជាតិប៉ូឡូញអង្គនេះឡើយ”។ សម្តេចព្រះមហាវរក្សត្រកម្ពុជាបានជួបធ្វើសវនាការម្តង ជាមួយសម្តេចប៉ាបយ៉ូហាន ប៉ូលទី២ កាលពីនៅក្នុងអំឡុងទសវត្សទី៨០។

វិបសាយ ព្រះមហាវរក្សត្រ



Photo: DR

# សម្តេចប៉ាបថ្មីទាក់ទាញអារម្មណ៍គ្រិស្តបរិស័ទ



Photo: DR

## ព្រះរាជសុន្ទរកថា លើកដំបូងរបស់ សម្តេចប៉ាបបេណេឌីក ទី១៦

"បងប្អូនជាទីស្រឡាញ់បន្ទាប់ពីការចូលទិវង្គតរបស់សម្តេចប៉ាបយ៉ូហាន ប៉ូលទី២ ដ៏មហាអស្ចារ្យរបស់យើងមក លោកកាឌីណាល់ទាំងអស់បានបោះឆ្នោតជ្រើសតាំងខ្ញុំជាអ្នកបំរើដ៏សុភាពរាបសាសាមញ្ញ នៅក្នុងចំការរបស់ព្រះជាម្ចាស់។ ជាពិសេសនោះ ខ្ញុំមានសេចក្តីសង្ឃឹមទាំងស្រុងទៅលើការអធិដ្ឋានរបស់បងប្អូន។ ទោះបីជាខ្ញុំមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការណែនាំព្រះសហគមន៍របស់ព្រះអង្គ ក៏ទ្រង់ផ្តល់នូវកំលាំងចិត្ត សេចក្តីសង្ឃឹម និង បំភ្លឺផ្លូវខ្ញុំ នូវរបៀបបំពេញបេសកកម្ម ដើម្បីបំរើព្រះសហគមន៍។ ដោយសារតែព្រះជាអម្ចាស់មានព្រះជន្មរស់ឡើងវិញ យើងមានជំនឿយ៉ាងមុតមាំថាព្រះជាម្ចាស់នឹងជួយបំភ្លឺផ្លូវ ដោយគង់នៅជាមួយយើងជានិច្ចដើម្បីឱ្យយើងអាចដឹកនាំព្រះសហគមន៍បន្តដំណើរទៅមុខទៀត។ សូមព្រះនាងម៉ារីជាមាតា ដ៏ជាទីស្រឡាញ់របស់ព្រះជាម្ចាស់គង់នៅជាមួយយើង។ សូមអរព្រះគុណ"។

### លោកអភិបាល អេមីលដេតម្ប

"ខ្ញុំមានសេចក្តីអំណរសប្បាយ ចំពោះបេក្ខភាពសម្តេចប៉ាបថ្មី។ តាមពិតខ្ញុំធ្លាប់បានជួបព្រះភ័ក្ត្រព្រះអង្គម្តងនៅបុរីវ៉ាទីកង់។ ព្រះអង្គគឺជាមនុស្សមានបញ្ញាឆ្លាតវាងវៃ និងស្មោះត្រង់។ ខ្ញុំសង្ឃឹមថា សម្តេចប៉ាបបេណេឌីក ទី១៦ នឹងនៅតែបន្តព្រះរាជបេសកកម្មណែនាំព្រះសហគមន៍ ដូចសម្តេចប៉ាបយ៉ូហាន ប៉ូលទី២ ធ្លាប់ធ្វើនៅពេលកន្លងមកក្នុងការបង្រួបបង្រួមគ្រិស្តសាសនិកគ្រប់ទិសទី ដោយការធ្វើកិច្ចសន្ទនាអន្តរសាសនានានា និងដើរតួនាទីដ៏សំខាន់មួយក្នុងការស្វែងរកសន្តិភាពជូនដល់ពិភពលោក" ។

## ជីវប្រវត្តិសង្ខេបសម្តេចប៉ាប បេណេឌីក ទី១៦

ឆ្នាំ១៩២៧: លោក យ៉ូស៊ែប រ៉ាតហ្ស៊ីង្គើ Joseph Ratzinger ប្រសូតនៅតំបន់ Marktl am Inn ប្រទេសអាឡឺម៉ង់។

១៩៤៦-១៩៥១: លោកបានសិក្សាទស្សនវិជ្ជា និង ទេវវិទ្យានៅសកលវិទ្យាល័យម៉ូនិច Munich។

១៩៥១: លោកបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ។

១៩៥៣: លោកបានទទួលសញ្ញាប័ត្រថ្នាក់បណ្ឌិតទេវវិទ្យា ដោយលោកសរសេរនិក្ខេបបទដែលមានចំណងជើងថា: "មនុស្ស និង ព្រះរាជដំណាក់របស់ព្រះជាម្ចាស់ នៅក្នុងទ្រឹស្តីនៃព្រះសហគមន៍របស់ សន្ត Augustine អូគ្ហីស្ទីន"។

១៩៥៩-១៩៦៧: លោកបានក្លាយជាសាស្ត្រាចារ្យបង្រៀនទេវវិទ្យា ដែលពន្យល់អំពីគោលការណ៍ដ៏សំខាន់ នៃគ្រិស្តសាសនា និងប្រវត្តិនៃគោលជំនឿ នៅសកលវិទ្យាល័យ Bonn, Tubinga និង Regensburg ប្រទេសអាឡឺម៉ង់។

១៩៦២: លោកបានក្លាយទៅជាទីប្រឹក្សារបស់លោកអគ្គអភិបាល Cologne និង លោកកាឌីណាល់ យ៉ូស៊ែប ហ្វ្រីង។

១៩៧៧: សម្តេចប៉ាប ប៉ូលទី៦ ជ្រើសតាំងគាត់ជាអគ្គអភិបាលប្រចាំទីក្រុងមុយនិច។

១៩៨១: សម្តេចប៉ាបយ៉ូហាន ប៉ូលទី២ តែងតាំងលោកជាប្រធានក្រុមគ្រួសារសំរាប់បព្វជិតលទ្ធិនៃជំនឿ ប្រធានគណៈកម្មការព្រះគម្ពីរសាមណសក្តិ និងគណៈកម្មការទេវវិទ្យាអន្តរជាតិ។

២០០២-២០០៥: លោកត្រូវជ្រើសតាំងជាព្រឹទ្ធបុរសសកលវិទ្យាល័យ កាឌីណាល់។

នៅថ្ងៃទី១៩ មេសា ២០០៥: លោកត្រូវបានជ្រើសតាំង ជាសម្តេចប៉ាប បេណេឌីក ទី១៦ នៅទីក្រុងរ៉ូម។











Photo: DR

### លោកឪពុក ប៉ុងស្វង់

"ខ្ញុំយល់ថាជាការល្អប្រសើរណាស់ក្នុងការជ្រើសរើសលោកកាឌីណាល់យូស៊ែប រ៉ាតហ្ស៊ីហ្គី ឱ្យធ្វើជាសម្តេចប៉ាបថ្មី។ ព្រះវិញ្ញាណបានជ្រើសតាំងលោកឱ្យក្លាយជាអ្នកណែនាំព្រះសហគមន៍ទូទាំងពិភពលោក។ សម្តេចប៉ាប បេណេឌីក ទី១៦ ជាទេវវិទូដ៏ល្បីល្បាញ និងមានប្រាជ្ញាឈ្លាសវៃ ហើយលោកធ្លាប់មានបទពិសោធន៍ជាទីប្រឹក្សាអតីតសម្តេចប៉ាប និងជាសាស្ត្រាចារ្យសកលវិទ្យាល័យ។ ទោះបីជាព្រះអង្គប្រកាន់គំនិតអភិរក្សនិយម ដូចជាសម្តេចប៉ាប យ៉ូហាន ប៉ូលទី២ ក៏ដោយ ខ្ញុំមានជំនឿថា ព្រះអង្គអាចណែនាំព្រះសហគមន៍បានល្អនៅក្នុងយុគសម័យនៃសហសវត្សរ៍ថ្មីនេះ"។

### អ្នកស្រី ច័ន្ទ សាមឿន

អ្នកស្រីជានាយិកាវិទ្យុគ្រួសារ FM 99.5 MHz ។ អ្នកស្រីបាននិយាយថា: "ខ្ញុំសូមអបអរសាទរ។ ដោយបានរង់ចាំតាមដានការជ្រើសរើសសម្តេចប៉ាបអស់រយៈពេលយ៉ាងយូរ ខ្ញុំសង្ឃឹមថា សម្តេចប៉ាបថ្មីនឹងបន្តធ្វើការងារដ៏ល្អសំរាប់ពិភពលោក ក្នុងការស្វែងរកសន្តិភាព។ នេះជាឱកាសមួយដ៏ល្អ។ យើងត្រូវលើកទឹកចិត្ត និងអធិដ្ឋានចំពោះគម្រោងការរបស់ព្រះជាម្ចាស់។ ខ្ញុំសង្ឃឹមថានៅថ្ងៃណាមួយ សម្តេចប៉ាបនឹងយាងមកប្រទេសកម្ពុជាយើង"។ តាំងនាមជាគ្រិស្តបរិស័ទនិកាយប្រូតេស្តង់ ខ្ញុំសូមសម្តែងអំណរសប្បាយជាមួយបងប្អូនគ្រិស្តបរិស័ទនិកាយកាតូលិកដែលទទួលបានសម្តេចប៉ាបថ្មី បេណេឌីក ទី១៦។

### លោកឪពុក ង៉ែត វិន័យ

"ខ្ញុំពេញចិត្តចំពោះបេក្ខភាពសម្តេចប៉ាប បេណេឌីក ទី១៦ យ៉ាងខ្លាំង។ វត្តមានរបស់សម្តេចនឹងអាចបង្រួបបង្រួមព្រះសហគមន៍ និងគ្រិស្តបរិស័ទគ្រប់និកាយមិនឱ្យបែកបាក់គ្នា។ កន្លងមកថ្វីបើមានសាធារណមតិ និងសារព័ត៌មានខ្លះរិះគន់ប្រៀបប្រដូចសម្តេចជាឆ្កែប៉ែហ្សេអាឡឺម៉ង់ក៏ដោយ ក៏ខ្ញុំនៅតែមានគោលជំហរ ស្រលាញ់ពេញចិត្តព្រះអង្គ ពីព្រោះព្រះអង្គមានសមត្ថភាពខ្ពស់ និងប្រាជ្ញាឈ្លាសវៃ។ ខ្ញុំតែងតែធ្វើការអធិដ្ឋានទូលអង្វរព្រះជាម្ចាស់សូមឱ្យសម្តេចប៉ាបថ្មីដែលមានវ័យចំណាស់នៅតែមានកម្លាំងកាយពលមាំមួនក្លាហានដើម្បីជម្នះនូវអស្រែកដ៏ធ្ងន់ធ្ងរ ដោយធ្វើជាអ្នកបំរើដ៏សុភាពរាបសា និងសាមញ្ញជាទីបំផុតរបស់ព្រះជាម្ចាស់"។

អត្ថបទរាយការណ៍ដោយ សំ វ៉ានី

## សារលិខិតសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី!

នៅក្នុងសារលិខិតកាលពីថ្ងៃពុធ ទី២៧ មេសា ផ្ញើជូនសម្តេចប៉ាបបេណេឌីក ទី១៦ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានបង្ហាញអំពី "ការរំជួលចិត្ត និងអំណរដែលព្រះសហគមន៍កាតូលិកកម្ពុជាបានសម្តែងឡើង"។

សម្តេចព្រះបរមនាថ នរោត្តមសីហមុនី បានបន្តថា: "ភាពរំជួលចិត្តដែលមានក្រោយពីមរណភាពរបស់សម្តេចប៉ាប យ៉ូហាន ប៉ូលទី២ បានបញ្ជាក់ច្បាស់ថា ខ្លឹមសារសំដីរបស់អ្នកស្នងតំណែងបន្តនៅវិមាន Saint-Pierre មិនត្រឹមតែធ្វើឱ្យអ្នកដែលមានជំនឿចាប់អារម្មណ៍ប៉ុណ្ណោះទេ ប៉ុន្តែ សំដីនេះបានផ្សព្វផ្សាយទៅឆ្ងាយទៀតដល់ខាងក្រៅព្រះសហគមន៍។ ទោះបី លទ្ធិសំភារៈនិយមកាន់តែកើនឡើង និងជំនឿសាសនាផ្សេងៗមានភាពច្របូកច្របល់គ្នានៅក្នុងពិភពលោកយើងយ៉ាងណាក្តី ក៏ខ្លឹមសារសំដីនេះនៅដក់ជាប់ក្នុងចិត្តយើងទាំងអស់គ្នា និងប្រជាជនដែលពួកគេកំពុងតែបន្តសាបព្រោះគំនិតនេះក្នុងចំណោមអ្នកមានជំនឿដូចគ្នាតាមផ្លូវវិញ្ញាណ"។

សម្រង់ពីកំបូជស៍រ

## សេចក្តីអំណរចំពោះសម្តេចប៉ាបថ្មី



Photo: DR

ព្រះសហគមន៍កាតូលិកជាស្ថាប័នសាសនាមួយ ដែលមានបទពិសោធន៍ជាង២០០០ឆ្នាំ ក្នុងការដឹកនាំជំនឿរបស់គ្រិស្តបរិស័ទ ហើយនិងបានជួយបង្កើតនូវច្បាប់អន្តរជាតិនានា ដែលមានមូលដ្ឋានចេញពីគោលការណ៍នៃគ្រិស្តសាសនា ដូចជា ការគោរពនូវសេរីភាព សាមគ្គីភាព ការយកចិត្តទុកដាក់ដល់អ្នកក្រីក្រ សេចក្តីស្រឡាញ់ និងការអភិវឌ្ឍន៍។ល។ អង្គការសហប្រជាជាតិទទួលស្គាល់សម្តេចប៉ាបថាជាមេដឹកនាំរដ្ឋមួយហៅថា បុរីវ៉ាទីកង់។ ក្រោយពីសម្តេចប៉ាបយ៉ូហាន ប៉ូលទី២ សោយទិវង្គត ឆ្នោតជ្រើសរើសសម្តេចប៉ាបថ្មីក៏បានចាប់ផ្តើម។ លោកកាឌីណាល់ Joseph Ratzinger ត្រូវបានជ្រើសរើសជាសម្តេចប៉ាបថ្មីដែលយកព្រះនាមថា BENEDICTO XVI។ លើព្រឹត្តិការណ៍នេះលោកអភិបាលអេមីល ដេតម្បមានប្រសាសន៍ថា: "ការជ្រើសតាំងសម្តេចប៉ាបថ្មីនឹងនាំមកនូវអំណរសប្បាយ និងក្តីសង្ឃឹមថ្មីដល់ព្រះសហគមន៍កម្ពុជា។ ខ្ញុំសូមឱ្យបងប្អូនរួបរួមគ្នានឹងព្រះសហគមន៍ទូទាំងពិភពលោកដើម្បីអរគុណព្រះជាម្ចាស់។ សូមអធិដ្ឋានចំពោះព្រះវិញ្ញាណដ៏វិសុទ្ធ ឱ្យជួយសម្តេចប៉ាបថ្មី ក្នុងបេសកកម្មណែនាំព្រះសហគមន៍ដើម្បីជម្នះនូវរាល់ឧបសគ្គទាំងឡាយដែលខ្លួនកំពុងតែប្រឈមមុខនាពេលបច្ចុប្បន្ននេះ"។ រីឯលោកឪពុកប្រ៊ុយណូមានប្រសាសន៍ថា: "ការបោះឆ្នោតរើសសម្តេចប៉ាបថ្មីនេះជាឱកាសដ៏សំខាន់មួយសំរាប់ប្រជាជនខ្មែរ ឱ្យដឹងអំពីព្រះសហគមន៍កាតូលិក និងសហគមន៍គ្រិស្តបរិស័ទនៅក្នុងបរិបទអន្តរជាតិ។ ប្រជាជនកម្ពុជាជាច្រើនបានយល់ជ្រួតជ្រាបរួចហើយថាព្រះសហគមន៍កាតូលិកមានលក្ខណៈជាសកល"។

លោកឪពុក អូមែរ

# របៀបជ្រើសតាំងសម្ដេចប៉ាបថ្មី

លោកកាឌីណាល់ Joseph Ratzinger ត្រូវបានជ្រើសតាំងជាសម្ដេចប៉ាបទី ២៦៦ ក្នុងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនាថ្ងៃទី១៩ ខែមេសា ក្រោយពីការចូលទិវង្គតរបស់សម្ដេចប៉ាបយ៉ូហាន ប៉ូលទី២។ តើគេបោះឆ្នោតជ្រើសតាំងសម្ដេចប៉ាបធ្វើឡើងយ៉ាងដូចម្ដេច? ខាងក្រោមនេះគឺជាចម្លើយ អំពីរបៀបជ្រើសរើសប្រមុខថ្មីរបស់គ្រិស្តបរិស័ទកាតូលិកជាង ១កោដិនាក់ នៅលើពិភពលោក។









រូបពីឆ្វេងទៅស្ដាំៈ តុរបស់លោកកាឌីណាល់ បង្ហុយផ្សែង ឡដុតសន្លឹកឆ្នោត រគាំងឱ្យដំណឹង និងសម្ដេចប៉ាបថ្មី ស្វាគមន៍មហាជន។



Photo: DR

## ១.ជំនួបក្នុងអង្គសន្និបាត

លោកកាឌីណាល់ទាំងអស់ ជាអ្នកបោះឆ្នោត ត្រូវមកជួបជុំគ្នានៅក្នុងអំឡុងពេល១៥ថ្ងៃ ក្រោយពីថ្ងៃចូលទិវង្គតរបស់អតីតសម្ដេចប៉ាបនៅ Chapelle Sixtine នាបុរី វ៉ាទីកង់ ទីក្រុងរ៉ូម ដែលជាកន្លែងសំរាប់រៀបចំការបោះឆ្នោត។

### បញ្ចប់ការស្នាក់នៅរួមគ្នា

លោកកាឌីណាល់ទាំងអស់លែងស្នាក់នៅក្នុងបន្ទប់ដ៏ធំ ដូចពីមុន ដែលជាធម្មតាត្រូវរៀបចំឡើងជាបន្ទប់នៅរួមគ្នា។

### ទូរស័ព្ទដៃត្រូវបានហាមឃាត់

ការធ្វើដំណើររបស់លោកកាឌីណាល់ ពីទីកន្លែងស្នាក់នៅទៅកាន់វិមាន Sixtine ត្រូវគោរពតាមបទបញ្ជាកំណត់។ ពួកលោកមិនអាចទាក់ទងជាមួយពិភពខាងក្រៅបានឡើយ។

## ២.តើនរណាអាចបោះឆ្នោត?នរណាអាចឈរឈ្មោះ?

គឺក្រុមលោកកាឌីណាល់ក្រោមអាយុ៨០ឆ្នាំ ដែលមានសិទ្ធិបោះឆ្នោត ហើយត្រូវបានកំណត់មិនឱ្យលើសពី ១២០ រូបឡើយ។ ការបោះឆ្នោតធ្វើឡើងជាសម្ងាត់។ បេក្ខជនជាប់ឆ្នោតត្រូវការនូវសម្លេងគាំទ្រ ២ភាគ៣ ក្នុងចំណោមសម្លេងឆ្នោតទាំងអស់។

បេក្ខជនដែលត្រូវគេជ្រើសរើស មិនចាំបាច់ ទាល់តែជាសមាជិកនៃអង្គសន្និបាតនោះទេ។ តាមច្បាប់ លោកអាចត្រូវបានរើសពីក្រៅក្របខណ្ឌ លោកកាឌីណាល់ ប៉ុន្តែ ក្នុងលក្ខខណ្ឌគឺទាល់តែលោកគឺជាបូជាចារ្យសាសនាកាតូលិក។

### បុរី វ៉ាទីកង់

ស្ថិតនៅលើទំហំដី ៤៤ ហិចតា នៅក្នុងទីក្រុងរ៉ូម ប្រទេសអ៊ីតាលី។ នេះគឺជារដ្ឋមួយ ដែលមានសម្ដេចប៉ាបជាអ្នកកាន់ទាំងអំណាចនីតិបញ្ញត្តិ និងនីតិប្រតិបត្តិតាមរយៈគណៈកម្មការនៃលោកកាឌីណាល់។

## ៣.ដំណើរប្រព្រឹត្តិទៅនៃការបោះឆ្នោត

នៅថ្ងៃកំណត់ អង្គសន្និបាតនឹងចាប់ផ្ដើមឡើង ដោយការធ្វើអភិបូជាមួយដែលប្រារព្ធឡើងជាពិសេស។

### "ទាំងអស់គ្នាស្ថិតនៅខាងក្រៅ"

នៅថ្ងៃទី១នៃអង្គសន្និបាត នៅពេលដែលលោកកាឌីណាល់ទាំងអស់បានធ្វើសច្ចាប្រណិធានរួចហើយ។ ពាក្យ Extra omnes (ទាំងអស់គ្នាចេញទៅក្រៅ) ត្រូវបានបន្លឺឡើង : អ្នកគ្មានភារកិច្ចក្នុងអង្គសន្និបាតត្រូវចេញទៅក្រៅ។

### "ខ្ញុំបោះឆ្នោតជ្រើសតាំងលោក...ជាសម្ដេចប៉ាប"

នៅពេលរសៀលថ្ងៃទី១ ការបោះឆ្នោតជុំទីមួយ នឹងប្រព្រឹត្តទៅ។ ហើយនៅថ្ងៃបន្តបន្ទាប់ការបោះឆ្នោត២ជុំ នឹងប្រព្រឹត្តឡើងនៅពេលព្រឹក និង២ជុំទៀតធ្វើនៅពេលល្ងាច។ អ្នកបោះឆ្នោតម្នាក់ៗ សរសេរឈ្មោះ ដែលជាជម្រើស របស់ខ្លួនលើសន្លឹកឆ្នោតរួចទម្លាក់វាទៅក្នុងហិបមួយ។ ក្រោយពីរាប់រួច សន្លឹកឆ្នោតនឹងត្រូវគេដុត។ ផ្សែងរបស់វានឹងត្រូវបង្ហុយចេញមកខាងក្រៅសាលដើម្បីបង្ហាញលទ្ធផល។

### ផ្សែងស ផ្សែងខ្មៅ

ផ្សែងស តំណាងឱ្យការបោះឆ្នោតអាចសំរេចជ្រើសរើសបានសម្ដេចប៉ាបថ្មី។ ផ្សែងខ្មៅតំណាងឱ្យការបោះឆ្នោតនៅតែត្រូវប្រព្រឹត្តទៅបន្តទៀត។ ប្រសិនបើបន្ទាប់ពី ៣ថ្ងៃ ហើយនៅតែរើសមិនបានបេក្ខជន។ ការបោះឆ្នោត នឹងត្រូវពន្យា ១ថ្ងៃទៀត។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើនៅតែទទួលបរាជ័យ លទ្ធផលនៃសម្លេងភាគច្រើនដាច់ខាតគឺពាក់កណ្ដាលនៃសម្លេងបូក១ នឹងត្រូវបានគេប្រកាន់យក។

## ៣. ការប្រកាសលទ្ធផល

នៅពេលមានបេក្ខជនជាប់ឆ្នោតហើយ ប្រមុខអង្គសន្និបាតទទួចសុំនូវការយល់ព្រមពីបេក្ខជននោះ និង សួរលោកថាៈ "ក្នុងនាមជាសម្ដេចប៉ាប តើលោកចង់យកព្រះនាមអ្វី?"

### "Habemus papam"

នៅពេលបេក្ខជនជាប់ឆ្នោតព្រមហើយ លោក កាឌីណាល់ម្នាក់នឹងទៅប្រកាសនៅឯមុខបង្អួចអគារ Saint-Pierreថា Habemus Papam (យើងមានសម្ដេចប៉ាបហើយ)។ អង្គសន្និបាតត្រូវបិទ។ សម្ដេចប៉ាបថ្មីនឹងទទួលបានអំណាចទាំងអស់តាមច្បាប់ដែលមានសំរាប់ព្រះអង្គ។

P.R

### ប្រវត្តិដើមអំពីតំណែងជាសម្ដេចប៉ាប

ថ្ងៃមួយ សាវ័ក សិលា អះអាងថា គាត់មានជំនឿយ៉ាងមុតមាំចំពោះព្រះយេស៊ូ។ ព្រះយេស៊ូនិយាយថាៈ "អ្នកគឺសិលា នៅលើសិលានេះយើងនឹងសាងសង់ព្រះសហគមន៍របស់យើង"។ ព្រះយេស៊ូចង់បង្ហាញដល់សាវ័កសិលាថា ព្រះអង្គផ្ដល់ឱ្យគាត់នូវអំណាចលើព្រះសហគមន៍។ ព្រះអង្គប្រាប់គាត់ថាៈ"យើងនឹងឱ្យកូនសោនៃស្ថានបរមសុខដល់អ្នក"។ សាវ័កសិលាជាអ្នកដឹកនាំព្រះសហគមន៍នៃគ្រិស្តបរិស័ទ ដំបូងៗនានា នៅទីក្រុងរ៉ូម។ សម្ដេចប៉ាបទាំងឡាយគឺជាអ្នកស្នងតំណែងពីគាត់បន្តបន្ទាប់។

## បញ្ហាអន្តរជាតិ

# លោកកូអ៊ីស៊ូមីសម្ដែងក្ដីក្លាហានសុំទោស ជាសាធារណៈ

**ជនជាតិចិនរាប់ម៉ឺននាក់បានធ្វើបាតុកម្មប្រឆាំងជប៉ុនទៅលើសៀវភៅសិក្សាប្រវត្តិសាស្ត្រខ្លះដែលបានអនុម័តឱ្យប្រើប្រាស់នៅក្នុងសាលានានារបស់ប្រទេសជប៉ុន។**

ហ្វូងបាតុករបានលើកឡើងថា សៀវភៅនេះគឺខ្វះនូវការពិត ដោយព្យាយាមបំលែងភាពពិតចំពោះទង្វើ ដែលជប៉ុនបានប្រព្រឹត្តនៅក្នុងសម័យសង្គ្រាម។ នៅទីក្រុង ណានជីង របស់ចិនមានអគាររំឭកវិញ្ញាណក្ខន្ធមួយសំរាប់ជនរងគ្រោះ ជាទីដែលបាតុករប្រកាសថាៈ "ក្នុងខែធ្នូ ឆ្នាំ១៩៣៧ ទីក្រុងណានជីង បានធ្លាក់ក្នុងកណ្ដាប់ដៃកងទ័ពរាជាអធិរាជជប៉ុន។ កងទ័ពជប៉ុនបានធ្វើការសម្លាប់រង្គាលក្នុងរយៈពេល ៦សប្ដាហ៍។ មានសាកសពមនុស្សស្លាប់ ក្រោយពីមានការសម្លាប់រង្គាលនេះ ដល់ទៅប្រមាណជា ៣០០.០០០នាក់ ដែលភាគច្រើនជាជនស៊ីវិល និង ឈ្លើយសឹកក៏ត្រូវបានសម្លាប់រង្គាល យ៉ាងកំណាចឃោរឃៅផងដែរ។ មានការចាប់រំលោភជាង ២០ ០០០ ករណី។ ជនរងគ្រោះជាច្រើនត្រូវបានចាប់រំលោភជាក្រុមៗ តួលេខនេះមិនទាន់បានរាប់បញ្ចូលចំពោះពេស្យាចារសំរាប់កងទ័ពនៅឡើយទេ"។

ភាពតានតឹងបានពុះពោរហូរហៀរទៅដល់ផងផ្លូវនានា នៃទីក្រុងជាច្រើនរបស់ចិន ដោយក្រុមហ៊ុនជប៉ុន បានក្លាយជាគោលដៅវាយប្រហារដោយបាតុកម្មហិង្សានានា។ ប្រទេសជប៉ុនបានទាមទារឱ្យចិនសុំទោសជាសាធារណៈចំពោះមហាបាតុកម្មនានា ដែលឈានដល់ទៅធ្វើឱ្យខូចខាតដល់ស្ថានទូតជប៉ុននៅប៉េកាំង ផ្ទុយទៅវិញចិនបានបដិសេធ ដោយបាននិយាយថា ជប៉ុនមិនដែលសារភាពអំពីអតីតកាលដ៏អាក្រក់របស់ខ្លួនឡើយដែលបានធ្វើឱ្យទំនាក់ទំនងចិន និងជប៉ុនធ្លាក់ចុះដល់កម្រិតទាបបំផុតក្នុងរយៈពេល ៣០ឆ្នាំនេះ។ ទោះបីជាយ៉ាងណាក៏ដោយ លោកកូអ៊ីស៊ូមី នាយករដ្ឋមន្ត្រី ជប៉ុនបានធ្វើការសុំទោសជាសាធារណៈ ចំពោះការរងទុក្ខសម័យសង្គ្រាមដែលជប៉ុនបានបង្កឡើងលើប្រជាជាតិអាស៊ី។

សំ វ៉ានី



លោកកូអ៊ី ស៊ូមី និងលោកប្រធានាធិបតីចិនហ៊ូ ជីនតាវ

Photo: DR

### ខួបលើកទី ៩០ ការសម្លាប់រង្គាលជនជាតិ Arménien

ជនជាតិ arménien រាប់ពាន់នាក់បានមកផ្ដុំគ្នាពីមុខបូជនីយដ្ឋានសំរាប់ឧទ្ទិសដល់ជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍នាឆ្នាំ១៩១៥។ ប្រទេសទួរគីមិនដែលមានភាពក្លាហានទទួលខុសត្រូវចំពោះទង្វើខ្លួនទេ។

# ភាពយន្តខ្មែរស្ថិតក្នុងភាពស្រពិចស្រពិល

**វិស័យភាពយន្តខ្មែរចាប់កំរើកឡើងវិញក្នុងឆ្នាំ២០០១ ក្រោយពីមានការឈប់ចាក់ផ្សាយរឿងភាគថៃតាមកញ្ចក់ទូរទស្សន៍។ ពីឆ្នាំ១៩៨៧ដល់ឆ្នាំ១៩៩០ ជាចន្លោះពេលវេលាមួយដែលវិស័យសិល្បៈទី៧ខ្មែរបានរីកដុះដាល។ ប៉ុន្តែដោយសារកុនទាំងឡាយត្រូវបានផលិតឡើងដោយចំណាយពេលខ្លី និងថវិកាតិចនោះ ធ្វើឱ្យវិស័យសិល្បៈភាពយន្តនេះបានដាំក្បាលចុះ។ លោកឫទ្ធី ប៉ាន ដែលជាសមិទ្ធិករ និងអ្នកដឹកនាំរឿងល្បីឈ្មោះលើឆាកអន្តរជាតិបានសម្តែងការបារម្ភចំពោះស្ថានការណ៍សិល្បៈភាពយន្តសព្វថ្ងៃ។**

**អ្នកនាំសារ:** តើទីផ្សារនៅក្នុងស្រុកមានភាពអំណោយផលដែរឬទេសំរាប់ភាពយន្តខ្មែរ?

**ឫទ្ធី ប៉ាន:** មិនជាណាស់ណាទេ! យើងត្រូវដឹងថាប្រជាជនខ្មែរមានតែ ១២លាននាក់។ ហើយរោងកុនភាគច្រើនមាននៅតែក្នុងទីក្រុងភ្នំពេញ។ ហើយមិនមែនប្រជាជនភ្នំពេញ២លាននាក់ទាំងអស់ទៅមើលកុននោះទេ ពោលគឺមានតែមនុស្សមួយចំនួនប៉ុណ្ណោះ ដែលមានលទ្ធភាពទិញសំបុត្រចូលទស្សនាក្នុងតម្លៃ៦០០០រៀលនោះ។ អ៊ីចឹង! ទីផ្សាររបស់យើងមិនជាធំណាស់ណានោះទេ។ បើយើងចង់ឱ្យមានមនុស្សច្រើន មើលកុន យើងត្រូវចេះពង្រីកទីផ្សារ ដូចជា ទីផ្សារអាស៊ី អឺរ៉ុប និងអាមេរិកជាដើម។ ប៉ុន្តែមុននឹងកុនយើងអាចឈានចូលទីផ្សាររោងកុនគេបាន វាក៏ទាមទារឱ្យកុនយើងមានគុណភាពល្អ ទាំងសម្លេង រូបភាព និងរបៀបលេង ដែលនៅត្រង់ចំនុចនេះយើងនៅមិនទាន់ប្រសប់នៅឡើយទេ។

**អ្នកនាំសារ:** តើអាចនិយាយបានទេថាយើងត្រូវការពឹងផ្អែកលើការបណ្តុះបណ្តាល?

**ឫទ្ធី ប៉ាន:** ត្រឹមត្រូវ! បើសិនកាលណាយើងឥតមានបច្ចេកទេសខាងវិស័យភាពយន្ត យើងពិតជាឥតមានសមត្ថភាព ពោលគឺខ្វះធនធានមនុស្ស។ ទាំងនេះមិនខុសពីពេលកន្លងទៅថ្មីៗនេះទេ ពេលផលិតកម្មធំៗ របស់អាមេរិក ឬបារាំងមកថតនៅស្រុកខ្មែរ ពួកគេបានជ្រើសរើសយកបុគ្គលិកអ្នកបច្ចេកទេសជនជាតិថៃឱ្យមកធ្វើការ។ ហេតុអ្វី? ពីព្រោះនៅទីនេះ ខ្វះអ្នកបច្ចេកទេសខាងសម្លេង រូបភាព ពន្លឺ។ល។ ផ្ទុយទៅវិញ បើយើងមានអ្នកបច្ចេកទេស ប្រកបដោយសមត្ថភាពពេញលេញពិតប្រាកដ គេនឹងធ្វើការជាមួយយើង។ ការថតកុនរបស់បរទេសនៅក្នុងស្រុកយើង គឺអាចស្វែងរកការងារឱ្យអ្នកបច្ចេកទេសយើង។ និយាយឱ្យខ្លី យើងបាត់ឱកាសច្រើន ក្នុងការធ្វើការជាមួយផលិតកម្មបរទេសដែលល្បីឈ្មោះ។ ដូច្នេះ យើងត្រូវចាប់ផ្តើមគិតគូរ បង្កើតសាលារៀនភាពយន្តសំរាប់បណ្តុះបណ្តាលកូនខ្មែរយើង។

## លោកឫទ្ធី ប៉ាន សមិទ្ធិករភាពយន្តខ្មែរ

លោកឫទ្ធី ប៉ាន កើតនៅទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៦៤។ ពេលខ្មែរក្រហមចូលមកកាន់កាប់ប្រទេស គាត់ទើបតែមានអាយុ១១ឆ្នាំប៉ុណ្ណោះ។ មកដល់ឆ្នាំ១៩៧៩ គាត់បានរត់ចេញពីប្រទេសកម្ពុជាទៅនៅជំរំជនភៀសខ្លួនក្នុងប្រទេសថៃ។ មួយឆ្នាំក្រោយមក គាត់បានទៅដល់ប្រទេសបារាំង ហើយបានចូលសិក្សានៅវិទ្យាស្ថានជាន់ខ្ពស់ភាពយន្តនៅក្នុងឆ្នាំ១៩៨៥។

ស្នាដៃជាខ្សែរឿង និងភាពយន្តឯកសាររបស់លោកសំខាន់ៗមាន:

ជំរំសាយធូឬជាយដែន (ឆ្នាំ១៩៨៩) កម្ពុជារវាងសន្តិភាពនិងសង្គ្រាម (ឆ្នាំ១៩៩២) អ្នកស្រែ (ឆ្នាំ១៩៩៣-៩៤) បុប្ផាណាសោកនាដកម្មរបស់ប្រទេសកម្ពុជា (ឆ្នាំ១៩៩៦) យប់មួយក្រោយសង្គ្រាម (ឆ្នាំ១៩៩៦-១៩៩៧) ទឹកដីនៃព្រលឹងវិលវល់ (ឆ្នាំ១៩៩៩) មន្ទីរស២១ម៉ាស៊ីនពេជ្ឈឃាដខ្មែរក្រហម (ឆ្នាំ២០០២) និងមនុស្សនៅអង្គរ (ឆ្នាំ២០០៣)។

**អ្នកនាំសារ:** យើងឃើញថាមានគេបញ្ចាំងរឿងខ្មោចជាច្រើនតាមរោងកុន។ តើនេះជាសញ្ញាអាក្រក់សំរាប់វិស័យភាពយន្ត?

**ឫទ្ធី ប៉ាន:** គេមិនធ្វើកុនដើម្បីតែបំពេញចិត្តអ្នកមើលនោះទេ ប៉ុន្តែគេត្រូវធ្វើកុនប្រកបទៅដោយគុណភាពខ្ពស់ ទោះបីកុននោះជាកុនស្នេហា កំប្លែង ឬមនោសញ្ចេតនាក៏ដោយ។ បើកុននោះល្អមើលប្រាកដជាអាចទាក់ទាញអារម្មណ៍ទស្សនិកជនបានច្រើន។ បញ្ហាសព្វថ្ងៃគឺ ភាគច្រើនយើងចម្លងកុន ពីបរទេសសុទ្ធសាធតែម្តង។ បើមិនអ៊ីចឹងទេ បើនរណាម្នាក់ធ្វើកុនរឿងខ្មោចនោះ ១០ផលិតកម្មផ្សេងទៀតផ្អើលធ្វើកុនខ្មោចតាមគ្នា។ ខ្ញុំនៅមិនយល់សោះពីអ្វី ដែលគេផ្អើលធ្វើតាមគ្នានេះ។ គួរយល់ថា ទំនិញនៅទីផ្សារ បើយើងដាក់មួយទៅហើយនោះ បើយើងដាក់១០ទៀតដូចគ្នា មនុស្សប្រាកដជាធុញទ្រាន់។ ដូច្នេះ វាសនាកុនខ្មែរពិតជាធ្លាក់ទឹកដូចពីកាលលើកមុនអ៊ីចឹង។ ដូច្នេះ បើយើងមានលទ្ធភាពបណ្តុះបណ្តាល អ្នកសរសេររឿង ធ្វើសេណារីយ៉ូ នោះជាការមួយល្អណាស់ ពីព្រោះធម្មជាតិនៅស្រុកខ្មែរអស្ចារ្យរួចទៅហើយ។ យើងទៅរកឯណាទៀត បើយើងក៏មានព្រៃឈើ ទឹកឈូ និងសមុទ្រដែរនោះ។

**អ្នកនាំសារ:** ដោយធ្លាប់បានសិក្សាផ្នែកភាពយន្តនៅប្រទេសបារាំង។ តើលោកមានចង់បង្កើតសាលាភាពយន្តនៅទីនេះដែរឬទេ?

**ឫទ្ធី ប៉ាន:** អ្ហ៎! ខ្ញុំមិនមែនជារដ្ឋាភិបាលទេ (សើច) ព្រោះរឿងបង្កើតសាលារៀនបណ្តុះបណ្តាល វាជាភារកិច្ចរបស់រដ្ឋ។ នៅពេលណាមួយដែលគេយល់ពីតម្លៃវប្បធម៌ថាជាផ្នែកមួយនៃចំណូលសេដ្ឋកិច្ចប្រហែលជាពេលនោះ គេនឹងអាចគិតគូរដល់ការបង្កើតសាលាភាពយន្ត។ បើយើងយល់ថា វិស័យវប្បធម៌គឺគ្មានប្រយោជន៍ដល់សេដ្ឋកិច្ចនេះជាការយល់ខុសហើយ។ បច្ចុប្បន្ន នាយកដ្ឋានភាពយន្តក៏មានគម្រោងរៀបចំជ្រើសរើសរកអ្នកដែលសរសេរសេណារីយ៉ូបានល្អ ដើម្បីយកគេមកបណ្តុះបណ្តាល។ ខ្ញុំអាចចូលរួមជួយផ្តល់ជាគំនិតយោបល់ ឬក៏ជួយអានសេណារីយ៉ូ នៅពេលណាដែលគេមានគម្រោងធ្វើបែបនេះ។

**អ្នកនាំសារ:** លោកបានធ្លាប់ផ្តល់គំនិតជួយដល់សមិទ្ធិករនៅក្នុងស្រុកដែរឬទេ?

**ឫទ្ធី ប៉ាន:** ខ្ញុំពិបាកនិយាយណាស់ ពីព្រោះអ្នកដឹកនាំរឿងសព្វថ្ងៃ គេមានរបៀបដឹកនាំផ្សេង។ ខ្ញុំគិតថា ថ្ងៃមួយពេលដែលសមិទ្ធិករខ្មែរយល់ថាត្រូវផលិតនូវអ្វីមួយដែលលើសពីរបៀបធ្វើវីដេអូដែលវាគ្រាន់តែមានជីវិតរស់បណ្តោះអាសន្ននោះ ពេលនោះទើបយើងអាចឆាប់និយាយគ្នាត្រូវ។ ហើយបែបនេះទើបខ្ញុំអាចជួយបាន ពីព្រោះការធ្វើភាពយន្តខ្នាតធំ គឺត្រូវការនូវបច្ចេកទេសច្រើនណាស់។ នេះមិនមែនជាការធម្មតាទេ ក្នុងការធ្វើកុន។ មុននឹងចេះថតកាមេរ៉ា ឬសម្លេង យើងត្រូវការរៀនសូត្រ យ៉ាងហោចណាស់ ក៏៤ឆ្នាំដែរ មិនខុសអ្វីពីការងារវិស្វករទេ។ ធ្វើកុនមែនទែន យើងត្រូវចំណាយពេលវេលា ក្នុងការអប់រំបណ្តុះបណ្តាល។ លើពិភពលោកយើងនេះ មិនទាន់មានសាលាណាបង្រៀន៣ខែចេះដឹកនាំកុននោះទេ។

**អ្នកនាំសារ:** លោកដែលគិតទេថាសាច់រឿងក្នុងកុនរបស់លោកហាក់ដូចតម្រូវតែអ្នករៀនបានជ្រៅជ្រះនោះ?

**ឫទ្ធី ប៉ាន:** វាអាស្រ័យទៅលើអារម្មណ៍ និងការពេញចិត្តរបស់អ្នកមើល។ អ្នកខ្លះចូលចិត្តមើលរឿងកាប់ចាក់ ខ្លះចូលចិត្តមើលរឿងកំសាន្ត។ ខ្ញុំធ្វើកុនមិនដែលគិតអំពីមនុស្សស្រទាប់លើក្រោមអ្វីទេ! កន្លងមក គេតែងបានយករឿងខ្ញុំទៅចាក់បញ្ចាំងជាសាធារណៈនៅទីលានមុខវត្តបុទុម ខ្លះទៀតចាក់ផ្សាយតាមទូរទស្សន៍ជាតិកម្ពុជាដូចជារឿងអ្នកស្រែនិងរឿងបុប្ផាណាទុក្ខសោកនាដកម្មរបស់ប្រទេសកម្ពុជាជាដើម។

អត្ថបទរាយការណ៍ បូលីន ដាវីដ



ការថតភាពយន្តឯកសារនៅសាលមហោស្រពជាតិទន្លេបាសាក់ចាស់ដែលបានឆេះហើយនោះ និង លោកឫទ្ធី ប៉ាន (រូបតូច)

Photo: P. Messa/ Davith

## កន្លែងតម្កល់ឯកសារមួយនឹងត្រូវបង្កើតឡើង

ចាប់ពីពេលនេះតទៅ រាល់ឯកសារទូរទស្សន៍ វិទ្យុ និងរូបថតនានា នឹងត្រូវដាក់តម្កល់ក្នុងបណ្ណាសារដ្ឋានមួយ (កន្លែងតម្កល់ឯកសារ) ក្នុងគោលបំណងជាប្រយោជន៍ដល់ការស្រាវជ្រាវសំរាប់ថ្ងៃអនាគត។

ស្ថាប័នថ្មីមួយនេះនឹងត្រូវរៀបចំបង្កើតឡើងស្ថិតនៅក្រោមចំណុះនៃនាយកដ្ឋានភាពយន្តរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

លោកឫទ្ធី ប៉ាន គឺជាអ្នកផ្តួចផ្តើមបង្កើតគំនិតសំរាប់គម្រោងនេះ។ មកទល់នឹងសព្វថ្ងៃនេះ កិច្ចសហការជាមួយអ្នកបច្ចេកទេស ក្នុងការធ្វើបណ្ណាសារដ្ឋាន សំរាប់តម្កល់ទុកឯកសារនេះគឺនៅកំពុងចរចាគ្នានៅឡើយ។

សមិទ្ធិករភាពយន្តរូបនេះក៏បានពន្យល់ឱ្យដឹងថា: “នៅតាមស្ថានីយទូរទស្សន៍នានានៅក្នុងស្រុកសព្វថ្ងៃ ចំពោះឯកសារនានា គេគ្រាន់តែថតចំលងកម្មវិធី ទុកចូលកាសែតវីដេអូធម្មតា(VHS) តែប៉ុណ្ណោះ។ តាមពិត ការធ្វើដូច្នេះ គឺយើងមិនអាចរក្សាទុកឯកសារបានយូរឡើយ ពីព្រោះចំពោះវីដេអូធម្មតា គឺវាឆាប់រលួយណាស់។ បើយើងគ្មានអ្វីរក្សាទុកទេនោះ ថ្ងៃក្រោយទៅ យើងនឹងគ្មានរូបភាពអ្វីជាឯកសារដែលនិយាយអំពីស្រុកខ្មែរយើងនោះទេ”។ ផលប្រយោជន៍ម្យ៉ាងទៀត នៃកន្លែងតម្កល់ឯកសារគឺយើងអាចរក្សាបាននូវអ្វីដែលមានសារៈសំខាន់ណាស់សំរាប់មនុស្សជំនាន់ក្រោយដែលចង់ដឹង។

លើសពីនេះទៅទៀតនោះ គឺគេអាចស្វែងរកឯកសារស្តីអំពីសិល្បករ បទចំរៀងបុរាណៗ ព្រមទាំងព្រឹត្តិការណ៍ផ្សេងៗ ដែលកន្លងផុតអស់រយៈពេលជាង៣០ឆ្នាំថ្លាយ ក៏បានដែរ។ ចំណែកអ្នកសារព័ត៌មាន ទាំងនៅក្នុងស្រុក និងក្រៅស្រុក ពួកគេអាចមានលទ្ធភាពមកស្រាវជ្រាវនូវឯកសារផ្សេងៗ ដែលជាតម្រូវការចាំបាច់សំរាប់ពួកគេនៅស្ថាប័ននេះ និងក៏អាចសុំទិញសិទ្ធិពីស្ថាប័ននេះផងដែរ។

## ការចុះសួរសុខទុក្ខបងប្អូនក្រីក្រ

សមាគមសន្ត វាំងសង់ឌីប៉ូល និងលោកបូជាចារ្យនៃព្រះសហគមន៍ភូមិភាគកំពង់ចាម បានចុះសួរសុខទុក្ខបងប្អូនអ្នកជំងឺ ចាស់ជរា អ្នកក្រីក្រ និងគ្រួសារដែលស្លាប់ដោយសារជំងឺអេដស៍ ចំនួន១០ គ្រួសារដែលរស់តាមខ្ទមតូចៗ ក្នុងភូមិដាច់ស្រយាលមួយនៅខេត្តកំពង់ចាមកាលពីថ្ងៃទី៣ មេសា ២០០៥។ ការចុះសួរសុខទុក្ខនេះក៏មាននាំយកនូវអំណោយ ទៅចែកជូនបងប្អូនទាំងនោះផងដែរ។ អ្នកស្រី រ៉ូស ជីព ដែលជាអ្នកសម្របសម្រួលសមាគមនៅកម្ពុជា បានមានប្រសាសន៍ថា: "ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី គ្រួសារមួយចំនួនមានហូបចុកគ្រប់គ្រាន់។ ប៉ុន្តែគ្រួសារក្រីក្រ និងចាស់ជរាគ្មានអ្វីហូបទេ"។ អ្នកស្រីបានសង្កត់ធ្ងន់ថាការចែកអំណោយនេះគឺមិនមែនជាការមួយដ៏សំខាន់នោះទេ អ្វីដែលសំខាន់នោះគឺ "ការចុះទៅសួរសុខទុក្ខ និងការបង្ហាញអំពីសេចក្ដីស្រឡាញ់"ចំពោះបងប្អូនទាំងនោះ។

ផាន់ ប៊ូរ៉ា

## លោកអេមីលមានជម្ងឺ!

"អ្នកនាំសារ" សូមអញ្ជើញបងប្អូនគ្រិស្តបរិស័ទទាំងអស់រួមគ្នាអធិដ្ឋានសំរាប់លោកអភិបាលអេមីល ដេតម្ប ដែលកំពុងសំរាកនៅក្នុងមន្ទីរពេទ្យនាទីក្រុងបាងកក ប្រទេសថៃ។ លោកមានការឈឺចាប់បន្តិចបន្តួចនៅត្រង់ឆ្អឹងខ្នងរបស់លោក។ ដូច្នេះសូមយើងអធិដ្ឋានដល់ព្រះជាម្ចាស់ សូមទ្រង់ប្រទានពរឱ្យលោកអភិបាលបានឆាប់ជាសះស្បើយផង។

## សិក្ខាសាលាអំពីកំណើតពិភពលោក

សិក្ខាសាលាសំរាប់គ្រូអប់រំជំនឿ ស្ដីអំពី "កំណើតពិភពលោក និងកំណើតរបស់មនុស្សតាមបែបវិទ្យាសាស្ត្រ និងតាមព្រះគម្ពីរ" បានប្រារព្ធធ្វើនៅព្រះសហគមន៍ផ្សារតូចកាលពីថ្ងៃទី១៨ដល់ ២២ ខែមេសា ឆ្នាំ២០០៥ កន្លងទៅ ដោយមានការចូលរួមពីសិក្ខាកាមជាគ្រូអប់រំជំនឿចំនួន ៣៣នាក់ ក្រោមការណែនាំរបស់ លោកឪពុកប៉ុង សូដ៏ បងស្រីហ្សឺល បែរត៍ និងលោកគ្រូដួង សារ៉ង្ស។ សិក្ខាសាលានេះមានគោលបំណងដើម្បីឱ្យគ្រូអប់រំជំនឿរិះគិតអំពីទ្រឹស្ដីតាមបែបវិទ្យាសាស្ត្រនៃកំណើតពិភពលោក និងមនុស្ស ដោយប្រៀបធៀបអត្ថន័យតាមជំនឿនៅក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់។ សិក្ខាសាលានេះបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ។ ជាទីបញ្ចប់ សិក្ខាកាមបានលើកសំណូមពរលើប្រធានបទលើកក្រោយស្ដីអំពីខ្មោចបិសាច "ព្រលឹង វិញ្ញាណ" ព្រមទាំងប្រវត្តិសាស្ត្រព្រះសហគមន៍ និងប្រទេសកម្ពុជាផងដែរ។

លី សុវណ្ណា

## ព្រឹត្តិការណ៍នឹងកើត!

**ខែឧសភា**

- ថ្ងៃ២៥ ប្រជុំលោកបូជាចារ្យ និងបងស្រី រួមជាមួយលោកអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម។ ប្រជុំចែករំលែកបទពិសោធន៍អំពីការអប់រំជំនឿកុមាររវាងលោកបូជាចារ្យដូនជី តំណាងគ្រូអប់រំជំនឿ និងលោកអភិបាលភូមិភាគបាត់ដំបង។
- ថ្ងៃ២៦ ប្រជុំគណៈកម្មការតំបន់នៅខេត្តកំពង់ចាម។
- ថ្ងៃ២៩ សិក្ខាសាលាគ្រូអប់រំជំនឿនៅកំពង់ធំ។ ក្មេង៧៣០នាក់ទទួលព្រះកាយនៅព្រះសហគមន៍ភ្នំពេញ។

**ខែមិថុនា**

- ថ្ងៃ០១ បុណ្យកុមារអន្តរជាតិមានការជួបជុំក្មេង ៣០០នាក់នៅកំពង់ចាម។
- ថ្ងៃ០៥ ពិធីតែងតាំងបងប្រុសយ៉ូហាន និងអ៊ីវ៉ាន់ជាឧបដ្ឋាកភ្នំពេញ។
- ថ្ងៃ៧-៩ សំណាក់ធម៌យុវជនជាមួយបងប្រុសហ្គីលឡាំងនៅក្តុលលើ។
- ថ្ងៃ១០-១១ សំណាក់ធម៌យុវជននិងបងប្រុសហ្គីលឡាំង នៅកំពង់ចាម។

## ប្រឡងគំនូរ

សូមអញ្ជើញប្រិយមិត្តអ្នកអានចូលរួមប្រឡងគូរគំនូរ!

លក្ខខណ្ឌ → បេក្ខជនអាយុ ៧ ទៅ១៦ឆ្នាំ។ ប្រធានបទ: ទេសភាពស្រុកស្រែ ឬការងារកសិករ។ គំនូរ: សខ្មៅ ឬពណ៌។ ប្រភេទក្រដាស: ក្រដាសអា៤ (A4) ឬសន្លឹកសៀវភៅ។ ផ្ញើមក: ព្រះសហគមន៍តាមរយៈលោកឪពុកដែលអ្នករស់នៅជិតបំផុត។ ថ្ងៃកំណត់: ៣០ សីហា ២០០៥។

ព្រឹត្តិបត្រអ្នកនាំសារ

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៩២ សង្កាត់ បឹងព្រលិត រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ អូមែរ ហ្សីរ៉ាល់ដូ